**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# សិទ្ធិបុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **នោ ដារ៉ូ**

សាស្ត្រាចារ្យណែនាំ
លោក **ឌិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **នោ ដារ៉ូ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

១.លោកឪពុកឈ្មោះ **ខិន នោ** និងអ្នកម្តាយឈ្មោះ **ស្រេង ស្រី** ដែលមានគុណូបការៈដ៏ឧត្តុង្គឧត្តម មិនអាចកាត់ថ្លៃបានសម្រាប់កូន។ បងប្រុសឈ្មោះ **នោ មូរ៉ា** ដែលបានឧបត្ថម្ភទំនុកបម្រុងទាំងថវិកា និងសម្ភារៈក្នុងការសិក្សានៅថ្នាក់មហាវិទ្យាល័យតាំងតែពីដើមដល់ចប់។ លោកតាឈ្មោះ **គា ឈឹន** ដែលបានចិញ្ចឹមបីបាច់ទំនុកបម្រុងចៅឱ្យបានសិក្សាតាំងតែពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់វិទ្យាល័យ និង សូមឧទ្ទិសស្នាដៃនិងកុសលផលបុណ្យទាំងពួងរបស់ចៅជូនដល់លោកយាយ **ភូយ យាន** ដែលបានចែកឋានទៅបរលោកទៅហើយ។

២.ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្រួលដល់ដំណើរការនៃការសិក្សា។

៣.លោក **ជិន វណ្ណារ៉ា** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាសាស្ត្រាចារ្យដឹកនាំសរសេរសារណា ដែលបានចំណាយពេលវេលាដ៏មានតម្លៃនិងយកអស់ពីកម្លាំងកាយចិត្តក្នុងការផ្តល់អនុសាសន៍ ចំណេះដឹង និងបទពិសោធន៍ល្អៗក្នុងការស្រាវជ្រាវ ដើម្បីចងក្រងបានជាសារណានេះឡើងប្រកបដោយគុណភាព។

៤.បងប្រុស **មិន សីហា** អនុប្រធានការិយាល័យ នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានជួយផ្តល់ជាយោបល់ល្អៗនៅក្នុងការសរសេរសារណានេះឡើង។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងពឹងពរវត្ថុស័ក្តិសិទ្ធិដែលមានក្នុងលោកទាំងអស់ សូមជួយប្រសិទ្ធពរជ័យដល់លោកអ្នកមានគុណ ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោក លោកស្រី អ្នកនាង កញ្ញា ឱ្យទទួលបានសុខភាពល្អបរិបូរណ៍ និងមានសុភមង្គលក្នុងក្រុមគ្រួសារ។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាក្រោមប្រធានបទស្ដីពី « **សិទ្ធិបុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត** » គឺជាចំណេះដឹងថ្មីមួយផ្នែកគតិយុត្ត ដែលបានធ្វើឡើងស្របទៅតាមកំណើននៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតក្នុងដំណាក់កាលបដិវត្តន៍ឧស្សាហកម្មទី៤។

ដើម្បីអាចចងក្រងសារណានេះឡើងប្រកបទៅដោយគុណភាពល្អ សម្រាប់ជាប្រយោជន៍ដល់សង្គមជាតិខ្មែរ និងបានបន្សល់ទុកជាឯកសារសម្រាប់អ្នកស្នេហាការសិក្សាក្រោយៗទៀត គឺខ្ញុំបាទបានខិតខំយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តស្វែងរកឯកសារនានាដែលពាក់ព័ន្ធ នៅតាមបណ្ណាល័យ ប្រព័ន្ធអ៊ីនធឺណិត ហើយនិងបានជួបពិភាក្សាសុំយោបល់ពីសាស្ត្រាចារ្យដឹកនាំផងដែរ។ ប៉ុន្តែយ៉ាងណាមិញ ទោះបីជាមានការខិតខំប្រឹងប្រែងសម្រិតសម្រាំងជាទីបំផុតក៏ដោយ ក៏ខ្ញុំបាទជឿថាអាចនឹងនៅមានចំណុចខ្វះខាតនៅឡើយ។ អាស្រ័យដូច្នេះ សូមឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ រៀមច្បង សិស្សប្អូនជំនាន់ក្រោយៗ និងមិត្តអ្នកសិក្សា មេត្តាអធ្យាស្រ័យលើការខ្វះខាតទាំងនោះផងចុះ និងធ្វើការរិះគន់ស្ថាបនាកែលម្អបន្ត ដើម្បីបានជាប្រយោជន៍សម្រាប់ទាំងអស់គ្នា។

ជាអវសានអារម្ភកថា ខ្ញុំសូមគោរពជូនពរដល់ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តអ្នកស្នេហាការសិក្សាឱ្យជួបតែសំណាងល្អ សម្រេចការងារតូចធំ និងជាពិសេស សូមទទួលបាននូវទ្រព្យសម្បត្តិដ៏មហាសាលនិងមិនអាចកាត់ថ្លៃបាន គឺ**សុខភាពល្អបរិបូរណ៍**។

សូមអរព្រះគុណ សូមអរគុណ...!

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


**១.លំនាំបញ្ហានៃការស្រាវជ្រាវ**..........១
**២.ចំណោទបញ្ហានៃការស្រាវជ្រាវ**..........២
**៣.គោលបំណងនៃការស្រាវជ្រាវ**..........២
**៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**..........២
**៥.សារៈសំខាន់នៃការស្រាវជ្រាវ**..........៣
**៦.វិធីសាស្ត្រនៃការស្រាវជ្រាវ**..........៣
**៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**..........៤


## ជំពូកទី១
## សញ្ញាណទូទៅនៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយ


**១.១.និយមន័យ**..........៥
**១.២.សញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ**..........៥
១.២.១.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស..........៥
១.២.២.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ..........៦
**១.៣.សញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា**..........៦
១.៣.១.ការទទួលស្គាល់សិទ្ធិលើការផ្សព្វផ្សាយដោយរដ្ឋធម្មនុញ្ញកម្ពុជា..........៦
១.៣.២.ការទទួលស្គាល់សិទ្ធិលើការផ្សព្វផ្សាយដោយច្បាប់ស្តីពីរបបសារព័ត៌មាន..........៧


## ជំពូកទី២
## ការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត


**២.១.សិទ្ធិនិងសេរីភាពរបស់បុគ្គលក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត**..........៨
**២.២.ដែនកំណត់នៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត**..........៩
២.២.១.ការផ្សព្វផ្សាយក្នុងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក..........៩
២.២.២.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌសារព័ត៌មាន..........១១
ក.ការហាមឃាត់លើការផ្សព្វផ្សាយតាមច្បាប់ស្តីពីរបបសារព័ត៌មាន..........១១
ខ.ក្រមសីលធម៌អ្នកសារព័ត៌មាន..........១២
២.២.៣.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌសុខាភិបាល..........១៣
ក.ការផ្សព្វផ្សាយពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា..........១៣
ខ.ការផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ..........១៣
គ.ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធឱសថ គ្រឿងសំអាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ..........១៤

ឃ.ការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់.......................................................១៦
២.២.៤.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌកម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ..................................................១៦
ក.ប្រភេទស្នាដៃដែលទទួលបានការការពារ.................................................................................១៧
ខ.ស្នាដៃដែលមិនទទួលបាននូវការការពារ.................................................................................១៨
គ.ការកម្រិតសិទ្ធិលើការផ្សព្វផ្សាយដែលប៉ះពាល់ដល់កម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ......................១៨
២.២.៥.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវប្បធម៌ជាតិ.........................................................................២១
ក.ការហាមឃាត់ចំពោះការផ្សព្វផ្សាយដែលប៉ះពាល់វប្បធម៌ជាតិ...................................................២១
ខ.ក្រមសីលធម៌នៃអ្នកសិល្បៈ...............................................................................................២២
២.២.៦.ការហាមឃាត់ការផ្សព្វផ្សាយជីវិតឯកជនរបស់បុគ្គល...........................................................២៥
២.២.៧.សិទ្ធិផ្សព្វផ្សាយតាមសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត...........................២៧
២.២.៨.ការគ្រប់គ្រង ការប្រឆាំង និងការទប់ស្កាត់លើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត..................២៨
ក.កាតព្វកិច្ចរបស់ក្រសួងព័ត៌មានលើការផ្សព្វផ្សាយខុសច្បាប់.....................................................២៩
ខ.កាតព្វកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍............................................................៣០
គ.កាតព្វកិច្ចរបស់ក្រសួងមហាផ្ទៃ..........................................................................................៣០
**២.៣.បទល្មើសនិងទោសចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត**..៣១
២.៣.១.វិសាលភាពនៃការផ្សព្វផ្សាយតាមវិធានពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក........................៣១
២.៣.២.ដែនអនុវត្តនៃការផ្សព្វផ្សាយតាមវិធានរបបសារព័ត៌មាន....................................................៣៣
២.៣.៣.វិសាលភាពនៃការផ្សព្វផ្សាយក្នុងវិស័យសុខាភិបាល.........................................................៣៣
ក.ការផ្សព្វផ្សាយពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា.......................៣៣
ខ.ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ.....................................................៣៤
គ.ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធឱសថ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវិជ្ជសាស្រ្ត...........................................................................៣៤
ឃ.ការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់.....................................................៣៥
២.៣.៤.វិសាលភាពនៃការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌកម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ.............................៣៥
២.៣.៥.ដែនអនុវត្តនៃការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវប្បធម៌ជាតិ......................................................៣៥
២.៣.៦.ក្របខ័ណ្ឌនៃជីវិតឯកជនរបស់បុគ្គល.............................................................................៣៦
២.៣.៧.ដែនកំណត់នៃការផ្សព្វផ្សាយតាមសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត.......៣៧
២.៣.៨.ការកំណត់បទល្មើស និងទោសផ្សេងៗទៀត..................................................................៣៧
**២.៤.ផលប៉ះពាល់នៃការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត**៣៩
២.៤.១.ទិដ្ឋភាពខាងសេដ្ឋកិច្ច..................................................................................................៣៩
ក.ផលវិជ្ជមាន........................................................................................................................៣៩
ខ.ផលអវិជ្ជមាន.....................................................................................................................៣៩

២.៤.២.ទិដ្ឋភាពខាងសង្គម ........................................................................................ ៤០
ក.ផលវិជ្ជមាន ........................................................................................ ៤០
ខ.ផលអវិជ្ជមាន ........................................................................................ ៤០
២.៤.៣.ទិដ្ឋភាពខាងវប្បធម៌ ........................................................................................ ៤២
ក.ផលវិជ្ជមាន ........................................................................................ ៤២
ខ.ផលអវិជ្ជមាន ........................................................................................ ៤២
**សេចក្ដីសន្និដ្ឋាន** ........................................................................................ ៤៣
**អនុសាសន៍** ........................................................................................ ៤៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ព័ត៌មានពិតជាមានសារៈសំខាន់សម្រាប់គ្រប់វិស័យដូចជាវិស័យសេដ្ឋកិច្ច នយោបាយ ការទូត ជាដើម។ កាលដើមឡើយ ការបញ្ជូនសារ ដំណឹង ពីមនុស្សម្នាក់ទៅម្នាក់ ពីក្រុមមួយទៅក្រុមមួយ ដែលនៅឆ្ងាយពីគ្នា គឺប្រើពេលវេលាយូរទម្រាំតែទទួលបាន ហើយក៏មានលក្ខណៈមិនសូវជាច្បាស់លាស់និងពេញលេញនោះទេ។ កាលពីសម័យនោះគេអាចផ្ញើសារតាមរយៈមធ្យោបាយផ្សេងៗដូចជា ការបញ្ជូនសារតាមសត្វព្រាប ការបញ្ជូនសារតាមអ្នកនាំសារ ឬការបញ្ជូនសារតាមផ្លែដូងទុំបោះបណ្ដែតតាមទឹកក៏មាន។ ទំនាក់ទំនងឆ្លើយឆ្លងព័ត៌មានរកគ្នាពីចម្ងាយនេះ ក៏ត្រូវបានកត់ត្រាតាមរយៈប្រវត្តិសាស្ត្រ អក្សរសិល្ប៍ រឿងព្រេង ប្រលោមលោក កំណាព្យ បទចម្រៀងផ្សេងៗ។ ជាក់ស្ដែង តាមរយៈលោក គង់ ប៊ុនឈឿន ដែលជាអ្នកនិពន្ធនិងជាកវីដ៏ល្បីល្បាញមួយរូប ទោះបីលោកបានទទួលមរណភាពក៏ដោយ តែស្នាដៃម្ចាស់ស្នឹងសង្កែរូបនេះ នៅតែជក់ចិត្តដិតអារម្មណ៍គ្មានថ្ងៃបំភ្លេចបាន។ ម្ចាស់ស្លាបប៉ាកកាឥន្ទ្រិយារម្មណ៍រូបនេះ បានរំលេចអត្ថន័យខ្លឹមសារ នៃការផ្ញើសារតាមចម្រៀងមួយបទដែលមានចំណងជើងថា "ស្ពានអូរតាគី" «...អូនតាមម្ដាយទៅមង្គលបុរី គ្មានផ្ញើសម្ដីឱ្យបងមួយម៉ាត់ បងជាកម្មកររថភ្លើងកម្សត់ បងជាកម្មកររថភ្លើងកម្សត់ លួចផ្ញើសំបុត្រតាមអ្នកឆត់ពន្ធ...»។

លុះដល់សម័យកាលចេះតែវិវឌ្ឍទៅៗ ឧបករណ៍មួយប្រភេទត្រូវបានបង្កើតឡើង គឺទូរស័ព្ទ។ គេអាចនិយាយរកគ្នាបានពីចម្ងាយ ពីកន្លែងមួយទៅកន្លែងមួយ ពីប្រទេសមួយទៅប្រទេសមួយទៀត។ រហូតមកដល់សម័យបច្ចុប្បន្ន ដោយសារការរីកចម្រើននៃបច្ចេកវិទ្យានិងនវានុវត្តន៍ថ្មីៗ មនុស្សអាចភ្ជាប់និងធ្វើទំនាក់ទំនងគ្នាពីចម្ងាយនៅជុំវិញពិភពលោកបានយ៉ាងងាយស្រួលតាមរយៈអ៊ីនធឺណិត។ លើសពីការឆ្លងឆ្លើយជាសំឡេង គេអាចផ្សព្វផ្សាយឬចែកចាយនូវព័ត៌មានផ្ទាល់ខ្លួន ព័ត៌មានសង្គម ធ្វើការកម្សាន្ត ធ្វើអាជីវកម្ម ឬធ្វើពាណិជ្ជកម្មជាដើម។ ទន្ទឹមនឹងការចែករំលែកព័ត៌មានយ៉ាងទូលំទូលាយនេះ គេក៏ឃើញមានបុគ្គលខិលខូចមួយចំនួន បានឆក់យកមធ្យោបាយប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតទៅប្រព្រឹត្តអំពើល្មើសផ្សេងៗដែលផ្ទុយនឹងច្បាប់រដ្ឋបានកំណត់។ ទង្វើរបស់ជនល្មើសទាំងនោះមានដូចជា ការផ្សព្វផ្សាយឬចែកចាយនូវព័ត៌មានមិនពិត ព័ត៌មានបែបញុះញង់ឱ្យមានហិង្សា ការរើសអើង ការស្អប់ខ្ពើម ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិសាសន៍ ឬឋានៈសង្គម។ ការធ្វើអាជីវកម្មតាមប្រព័ន្ធអ៊ីនធឺណិតដោយគ្មានអាជ្ញាបណ្ណនិងការទទួលស្គាល់ពីក្រសួង-ស្ថាប័នជំនាញ និងការដាក់លក់ផលិតផលដែលគ្មានគុណភាព ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់។ ការជេរប្រមាថ ការផ្សព្វផ្សាយឬការចែកចាយព័ត៌មានដែលធ្វើឱ្យប៉ះពាល់ដល់ព្រះកិត្តិសព្ទរបស់អង្គព្រះមហាក្សត្រ ប៉ះពាល់ដល់វប្បធម៌ប្រពៃណីជាតិ ស្ថាប័នជាតិ បុគ្គលសាធារណៈ ថែមទាំងកិត្តិយសនិងសេចក្ដីថ្លៃថ្នូររបស់បុគ្គលឯកជន។ លើសពីនេះទៅទៀត គឺការផ្សាយឬការចែកចាយនូវព័ត៌មាន

ដែលប៉ះពាល់ដល់សន្តិសុខជាតិ ស្ថិរភាពនយោបាយ ដែលអាចធ្វើឱ្យសង្គមជាតិទាំងមូលឈានទៅរកជម្លោះ និងសេចក្តីវិនាសអន្តរាយ។

ដោយសារមើលឃើញពីបញ្ហាទាក់ទងនឹងការផ្សព្វផ្សាយរបស់បុគ្គលតាមរយៈបណ្តាញអ៊ីនធឺណិតដែលកំពុងកើតមានឡើងនាពេលបច្ចុប្បន្ន ទើបប្រធានបទនេះត្រូវបានសម្រេចជ្រើសរើសដើម្បីចងក្រងជាសារណា។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវនិងឈ្វេងយល់ពីបញ្ហាដែលកើតមានឡើងនាពេលបច្ចុប្បន្នទាក់ទងនឹងការផ្សព្វផ្សាយរបស់បុគ្គលនៅលើប្រព័ន្ធអ៊ីនធឺណិត ធ្វើឱ្យការសិក្សាស្រាវជ្រាវកំណត់បាននូវចំណោទបញ្ហាសំខាន់ និងចំណោទបញ្ហាបន្ទាប់បន្សំមួយចំនួនដូចខាងក្រោម៖

- តើបុគ្គលអាចមានសិទ្ធិសេរីភាពផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិតយ៉ាងដូចម្តេច?
- តើក្នុងការផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត មានចំណុចណាខ្លះដែលបុគ្គលត្រូវចៀសវាង? សិទ្ធិនេះមានដែនកំណត់ដោយច្បាប់យ៉ាងដូចម្តេចខ្លះ?
- តើការផ្សព្វផ្សាយមិនគោរពច្បាប់លើប្រព័ន្ធអ៊ីនធឺណិតមានផលប៉ះពាល់អ្វីខ្លះដល់សេដ្ឋកិច្ច សង្គម និងវប្បធម៌ជាតិ?
- តើមានចំណុចអ្វីខ្លះ ដែលត្រូវកែលម្អទាក់ទងនឹងសិទ្ធិផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិត?

## ៣.គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទ «សិទ្ធិបុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត» គឺដើម្បីឈ្វេងយល់ពីមូលដ្ឋានសំខាន់ៗនៃសិទ្ធិរបស់បុគ្គលក្នុងការផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិត ឈ្វេងយល់ពីមូលដ្ឋានច្បាប់កំណត់ព្រំដែននៃការប្រើប្រាស់សិទ្ធិនេះ និងឈានទៅរកចំណុចខ្វះខាត ដើម្បីលើកជាយោបល់កែលម្អឡើងវិញ ទៅតាមបច្ចុប្បន្នភាពនៃការរីកចម្រើនរបស់សង្គមនាពេលបច្ចុប្បន្ន។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការសិក្សាស្រាវជ្រាវលើប្រធាន «សិទ្ធិបុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត» ផ្តោតសំខាន់លើការប្រើប្រាស់សិទ្ធិរបស់បុគ្គលចំពោះការផ្សព្វផ្សាយលើប្រព័ន្ធអ៊ីនធឺណិតតែប៉ុណ្ណោះ ដោយពុំបានគ្របដណ្តប់ទៅដល់ការប្រើប្រាស់សិទ្ធិរបស់បុគ្គលក្នុងការផ្សព្វផ្សាយតាមមធ្យោបាយផ្សេងពីនេះឡើយ និងការសិក្សាស្រាវជ្រាវមានដែនកំណត់នៃពេលវេលា ចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយសារសន្ទុះនៃការប្រើប្រាស់អ៊ីនធឺណិតនាពេលបច្ចុប្បន្នមានការកើនឡើងខ្លាំង ដែលធ្វើឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការផ្សព្វផ្សាយ ឬ ការចែកចាយខ្លឹមសារព័ត៌មាន ឬ សារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត។ ទន្ទឹមនឹងនេះដែរ វាក៏មានភាពងាយស្រួលដល់ការបង្កជាចលាចលបណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិ។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះ បានផ្តល់ផលប្រយោជន៍មួយចំនួនដូចខាងក្រោម៖

១.ចំពោះប្រជាពលរដ្ឋ៖ គឺជួយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីសិទ្ធិនិងច្បាប់ទៅលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ធ្វើឱ្យពួកគាត់ពុំមានទោសទណ្ឌដោយសារតែការចែកចាយព័ត៌មានមិនពិត ឬព័ត៌មានដែលប៉ះពាល់ដល់ជាតិ និងសិទ្ធិរបស់អ្នកដទៃ។

២.ចំពោះប្រទេសជាតិ៖ គឺការសិក្សាស្រាវជ្រាវបានរួមចំណែកក្នុងការផ្សព្វផ្សាយច្បាប់ឱ្យប្រជាពលរដ្ឋមានការយល់ដឹង។ នៅពេលដែលពួកគាត់យល់ដឹងអំពីច្បាប់ នោះរដ្ឋនឹងមានភាពងាយស្រួលក្នុងការគ្រប់គ្រងសង្គមឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ និងសេចក្តីថ្លៃថ្នូរ។

៣.ចំពោះអ្នកជំនាន់ក្រោយ៖ គឺការសិក្សាស្រាវជ្រាវនឹងបន្សល់ទុកបានជាឯកសារ និងអាចជាមូលដ្ឋានសម្រាប់អ្នកជំនាន់ក្រោយយកទៅសិក្សាស្រាវជ្រាវបន្ត និងកែលម្អឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះប្រើវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព(Qualitative Research) ដោយប្រើប្រភពទិន្នន័យបន្ទាប់បន្សំ(Secondary Data) តាមរយៈការស្រាវជ្រាវរកឯកសារជាសៀវភៅនិងអត្ថបទដែលបានបោះពុម្ពរួចនៅតាមបណ្ណាល័យនៃសាកលវិទ្យាល័យ បណ្ណាគារ និងកន្លែងធ្វើការ។ ឯកសារមួយចំនួនទៀតត្រូវបានស្រាវជ្រាវរកតាមរយៈប្រព័ន្ធអ៊ីនធឺណិត ជាសៀវភៅអេឡិចត្រូនិក(E-Book)និងអត្ថបទនៅលើគេហទំព័រ និងបណ្តាញទំនងទំនងសង្គមហ្វេសប៊ុក(Facebook)ផ្លូវការរបស់អង្គការ ក្រសួង-ស្ថាប័នជាតិ (ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល...) និងស្ថាប័នអន្តរជាតិ(អង្គការសហប្រជាជាតិ យូនីសេហ្វ ក្រុមប្រឹក្សាអឺរ៉ុប...)។

ដោយហេតុថា ពុំមានថវិកា និងមានពេលវេលាកំណត់ ដូច្នេះការសិក្សាស្រាវជ្រាវនេះ មិនបានប្រើប្រភពទិន្នន័យចម្បង(Primary Data) តាមរយៈការចុះស្ទង់មតិ(Survey)មហាជនផ្ទាល់ទេ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ «សិទ្ធិបុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត» បានធ្វើការរៀបចំជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ដែលចែកចេញជាពីរជំពូកធំៗ។ ជាបឋម គឺជាការបង្ហាញពីសញ្ញាណទូទៅនៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយ(ជំពូកទី១) ដែលការស្រាវជ្រាវបានសិក្សាទៅលើសញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយ ទាំងក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ និងច្បាប់របស់កម្ពុជា។ បន្ទាប់មកទៀត គឺការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត(ជំពូកទី២) ដោយបានសិក្សាផ្តោតលើសិទ្ធិនិងសេរីភាពដែនកំណត់នៃសិទ្ធិ បទល្មើសនិងទោស និងផលប៉ះពាល់នៃការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត។

# ជំពូកទី១
# សញ្ញាណទូទៅ
# នៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយ

# ជំពូកទី១
# សញ្ញាណទូទៅនៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយ

ជាបឋម ដើម្បីសិក្សាពីសញ្ញាណទូទៅនៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយ ការសិក្សាស្រាវជ្រាវសូមលើកយកមកបង្ហាញនូវ និយមន័យ(១.១) សញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ(១.២) និងសញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា(១.៣)។

## ១.១.និយមន័យ

ពាក្យ បុគ្គល គឺសំដៅទៅលើរូបវន្តបុគ្គល និងនីតិបុគ្គល។ រូបវន្តបុគ្គល គឺមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។[១] រីឯ នីតិបុគ្គល គឺក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ច។[២] ចំណែកឯ ផ្សព្វផ្សាយ មានន័យថា ផ្សាយដោយការប៉ះពាល់ត្រូវ, ផ្សាយផ្សព្វ, ជ្រួតជ្រាបគ្រប់អន្លើ។[៣] បើជាភាសាអង់គ្លេស ផ្សព្វផ្សាយ(Publicize) គឺជាការធ្វើអ្វីមួយឱ្យគេដឹងលឺជាសាធារណៈប្រកប្រៀ។[៤] ហើយនិងពាក្យថា អ៊ីនធឺណិត(Internet) គឺបណ្តាញកុំព្យូទ័រពិភពលោកដែលអាចឱ្យមនុស្សចែករំលែកព័ត៌មាន និងទាក់ទងគ្នាទៅវិញទៅមក។[៥]

## ១.២.សញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ

សិទ្ធិនៅក្នុងការផ្សព្វផ្សាយរបស់បុគ្គល ត្រូវបានទទួលស្គាល់ដោយច្បាប់អន្តរជាតិ។ ដូច្នេះ ការស្រាវជ្រាវបានលើកពីលិខិតបទដ្ឋានគតិយុត្តអន្តរជាតិមួយចំនួនមកសិក្សា ដែលមានដូចជា សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស(១.២.១) និងកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(១.២.២)។

### ១.២.១.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលបានអនុម័តកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ បានចែងកំណត់ជាលើកដំបូងបង្អស់អំពីសិទ្ធិ និងសេរីភាពជាមូលដ្ឋាន ដែលត្រូវទទួលស្គាល់ដោយរដ្ឋាភិបាល និងមនុស្សទាំងអស់នៅលើពិភពលោក។ សេចក្តីប្រកាសនេះ ក៏បានចែងអំពីការទទួលស្គាល់ទៅលើសិទ្ធិនៃការផ្សព្វផ្សាយ

---

[១] ទីស្តីការគណៈរដ្ឋមន្ត្រី, *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណីនិងនីតិវិធីរដ្ឋប្បវេណី*, បោះពុម្ពលើកទី១( ភ្នំពេញៈ គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, ឆ្នាំ២០០៧), ទំព័រទី១៩។

[២] សទ្ទានុក្រមដដែល, ទំព័រទី១០។

[៣] សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ*, បោះពុម្ពលើកទី៥(ភ្នំពេញៈ ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៧), ទំព័រទី៧១៦។

[៤] កម្មវិធីវចនានុក្រមអង់គ្លេសអេឡិចត្រូនិក Oxford Learner's Thesaurus Dictionary, (Oxford University Press, ឆ្នាំ២០០៤)។

[៥] ក្រុមប្រឹក្សាជាតិភាសាខ្មែរ, *សទ្ទានុក្រមវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ខ្មែរ-អង់គ្លេស-បារាំង* (ភ្នំពេញៈ ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាលនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ, ឆ្នាំ២០១៤), ទំព័រទី៧៩។

របស់បុគ្គលផងដែរ គឺមាត្រា១៩ បានបញ្ញត្តថា៖ "មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពនៃគំនិត និងការសម្តែងមតិ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាននិងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈធម្យោបាយសម្តែងមតិណាមួយក៏ដោយ។"

### ១.២.២.កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី១៦ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី២៣ខែមីនា ឆ្នាំ១៩៧៦។ កតិកាសញ្ញាអន្តរ-ជាតិនេះ បានទទួលស្គាល់សិទ្ធិលើការផ្សព្វផ្សាយរបស់បុគ្គលតាមមាត្រា១៩ ដែលបានបញ្ញត្តថា៖ "១.ជនគ្រប់រូប មានសិទ្ធិប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។ ២.ជនគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួលនិងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន..."។

## ១.៣.សញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងមានការគោរពសិទ្ធិមនុស្ស។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ត្រូវបានកម្ពុជាផ្តល់សច្ចាប័នទទួលយក។ ដូច្នេះ បទបញ្ញត្តិសិទ្ធិមនុស្ស ត្រូវបានកម្ពុជាចែងចូលទៅក្នុងច្បាប់ជាតិ ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ជាក់ស្តែង សិទ្ធិលើការផ្សព្វផ្សាយ ដែលជាផ្នែកមួយនៃសិទ្ធិមនុស្ស ក៏ត្រូវមានការទទួលស្គាល់ដោយច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា(១.៣.១) និងច្បាប់ស្តីពីរបបសារព័ត៌មាន(១.៣.២)។

### ១.៣.១.ការទទួលស្គាល់សិទ្ធិលើការផ្សព្វផ្សាយដោយរដ្ឋធម្មនុញ្ញកម្ពុជា

ក្នុងកម្រិតច្បាប់ជាតិ ច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់គ្រឹះនិងជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា ក៏បានចែងទទួលស្គាល់នូវសេរីភាពរបស់បុគ្គលខាងផ្សព្វផ្សាយផងដែរ។ យោងតាមមាត្រា៤១ កថាខណ្ឌទី១ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ញត្តថា៖ "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ...។"

ក្នុងន័យនេះ បង្ហាញថាបុគ្គលគ្រប់រូប ដែលជាពលរដ្ឋខ្មែរ អាចបញ្ចេញមតិរបស់ខ្លួន អាចផ្សព្វផ្សាយនូវសារ ដំណឹង ព័ត៌មាន អាចបោះពុម្ពផ្សាយ អាចប្រមូលផ្តុំគ្នា បានដោយគ្មានការបង្ខិតបង្ខំណាមួយឡើយ។

### ១.៣.២.ការទទួលស្គាល់សិទ្ធិលើការផ្សព្វផ្សាយដោយច្បាប់ស្តីពីរបបសារព័ត៌មាន

ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានទទួលស្គាល់នូវសេរីភាពនៃការផ្សព្វផ្សាយរបស់បុគ្គល។ មិនតែប៉ុណ្ណោះ ជាសញ្ញាណទៅលើការទទួលស្គាល់នៃសិទ្ធិនេះ មានច្បាប់ជាតិមួយទៀត ត្រូវបានបង្កើតឡើង គឺច្បាប់ស្តីពីរបបសារព័ត៌មាន។ ច្បាប់នេះ បានធានាដល់សេរីភាពបញ្ចេញមតិសម្រាប់សារព័ត៌មាន ឬការផ្សព្វផ្សាយរបស់បុគ្គល តាមមាត្រា១ ដោយបានបញ្ញត្តថា៖ "ច្បាប់នេះកំណត់របបសារព័ត៌មាន និងធានារ៉ាប់រងសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយឱ្យបានសមស្របតាមមាត្រា៣១ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។" បន្ថែមលើនេះទៀត មាត្រា៣ បានចែងការពារមិនឱ្យមានការត្រួតពិនិត្យមុនពេលបោះពុម្ពផ្សាយឡើយ។[៦] ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការ ដែលការផ្សាយមានលក្ខណៈត្រឹមត្រូវតាមរឿងពិត ពុំមានការផ្តន្ទាទោសឡើយ។[៧]

[៦] ច្បាប់ស្តីពីរបបសារព័ត៌មាន, លេខ នស/រកម/០៨៩៥/០៧, ០១ កញ្ញា ១៩៩៥, មាត្រា៣។

[៧] ច្បាប់ដដែល, មាត្រា៤។

# ជំពូកទី២
# ការអនុវត្តសិទ្ធិរបស់បុគ្គល
# លើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

# ជំពូកទី២
# ការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

នៅជំពូកបឋម ការសិក្សាស្រាវជ្រាវបានឈ្វេងយល់អំពីសញ្ញាណទូទៅនៃសិទ្ធិផ្សព្វផ្សាយរបស់បុគ្គល និងនៅជំពូកបន្ទាប់ នឹងផ្តោតទៅលើការប្រើប្រាស់សិទ្ធិផ្សព្វផ្សាយរបស់បុគ្គលនៅលើប្រព័ន្ធអ៊ីនធឺណិតវិញម្តង។ នៅត្រង់ជំពូកនេះ នឹងបង្ហាញអំពីៈ សិទ្ធិនិងសេរីភាពរបស់បុគ្គលក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត(២.១) ដែនកំណត់នៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត(២.២) បទល្មើសនិងទោសចំពោះការប៉ះពាន់សិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត(២.៣) ហើយនិងចុងក្រោយ គឺផលប៉ះពាល់នៃការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត(២.៤)។

## ២.១.សិទ្ធិនិងសេរីភាពរបស់បុគ្គលក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

សិទ្ធិនិងសេរីភាពលើការផ្សព្វផ្សាយ ត្រូវបានធានាដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។នៅក្នុងច្បាប់ជាតិមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា៤១ កថាខណ្ឌទី១ និងច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ ត្រង់មាត្រា១។ ម្យ៉ាងវិញទៀត សិទ្ធិនិងសេរីភាពនេះ ក៏មានចែងនៅក្នុងច្បាប់អន្តរជាតិផងដែរ គឺមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

គួរតែបញ្ជាក់ផងដែរ សិទ្ធិនិងសេរីភាពរបស់មនុស្ស អាចត្រូវបានលុបបំបាត់នៅពេលដែលពិភពលោកមានសង្គ្រាម។ ដើម្បីឱ្យមានការអនុវត្តសិទ្ធិមនុស្សនៅលើពិភពលោក គឺចាំបាច់ណាស់ត្រូវមានសន្តិភាព ដែលជាបុរេល័ក្ខខ័ណ្ឌដ៏ចាំបាច់ពុំអាចខ្វះបាន។ស្ថិតក្នុងតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ កម្ពុជា ជាប្រទេសដែលមានសន្តិភាព និងប្រកាន់យករបបដឹកនាំបែបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ហើយនិងអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលផ្តល់ឱ្យប្រជាពលរដ្ឋ មានសិទ្ធិនិងសេរីភាពដើរហើរ និងបញ្ចេញមតិជាសាធារណៈបានគ្រប់ទីកន្លែង ដោយរាប់បញ្ចូលទាំងសិទ្ធិនៅក្នុងការផ្សព្វផ្សាយផងដែរ។ ស្របជាមួយនឹងការវិវត្តនៃបច្ចេកវិទ្យា និង នវានុវត្តន៍ថ្មីៗ ដែលមានការវិវត្តទៅដល់បដិវត្តន៍ឧស្សាហកម្មទី៤ និងការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ជំនាន់ទី៥(5G) បានរុញច្រានឱ្យការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត[៨]មានការកើនឡើងគួរឱ្យកត់សម្គាល់។ ការណ៍នេះ ធ្វើឱ្យបុគ្គលអាចកាន់តែមានភាពងាយស្រួលនៅក្នុងការបញ្ចេញមតិ និងការផ្សព្វផ្សាយផ្សេងៗ។ ពលរដ្ឋជាច្រើនលាននាក់ក្នុងចំណោមពលរដ្ឋខ្មែរប្រមាណជាង១៥[៩]លាននាក់ បាននាំគ្នាប្រើប្រាស់អ៊ីនធឺណិតតាមទូរស័ព្ទដៃ កុំព្យូទ័រ និង

[៨] អ្នកប្រើប្រាស់អ៊ីនធឺណិតចល័តនៅកម្ពុជាមានចំនួន ១៥.៦ លាននាក់ យោងតាមគេហទំព័រ http://thekhmerdaily.com/article/46498, បានចុះផ្សាយនៅថ្ងៃច័ន្ទ ទី០៧ ខែតុលា ឆ្នាំ២០១៩, បានចូលពិគ្រោះនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០។

[៩] ក្រសួងផែនការ, *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩* (ភ្នំពេញៈ វិទ្យាស្ថានជាតិស្ថិតិ, ឆ្នាំ២០១៩), ទំព័រទី៩។

ឧបករណ៍បច្ចេកវិទ្យាផ្សេងៗទៀត ដើម្បីចូលទៅប្រើប្រាស់បណ្តាញសង្គមនានាដូចជាហ្វេសប៊ុក(Facebook) យូធូប(Youtube) និងអ៊ីនស្តាក្រាម(Instagram)ជាដើម។ ប្រព័ន្ធផ្សព្វផ្សាយតាមបែបប្រពៃណីមួយចំនួន ដែលមានដូចជាវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី ក៏ត្រូវបានជំនួសមកវិញដោយប្រព័ន្ធផ្សព្វផ្សាយបែបទំនើបនេះដែរ។ ហេតុនេះ សិទ្ធិនិងសេរីភាពលើការផ្សព្វផ្សាយរបស់បុគ្គល គឺមានភាពកាន់តែទូលំទូលាយ និងប្រសើរជាងមុន។

## ២.២.ដែនកំណត់នៃសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

បុគ្គលម្នាក់ៗអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនបានដោយសេរី ក្នុងព្រំដែនកំណត់របស់ច្បាប់។ ការប្រើប្រាស់សិទ្ធិដោយមិនគិតដល់ផ្លូវច្បាប់ គឺអនាធិបតេយ្យ។ មិនតែប៉ុណ្ណោះ ការប្រើប្រាស់សិទ្ធិលើសពីអ្វីដែលច្បាប់បានកំណត់ អាចជាការរំលោភបំពានទៅលើសិទ្ធិរបស់អ្នកដទៃ។ ដូច្នេះ ព្រំដែននៃសិទ្ធិ គឺច្បាប់ដែលរដ្ឋបានបញ្ញត្ត។ ពាក់ព័ន្ធនឹងសិទ្ធិក្នុងការផ្សព្វផ្សាយ ការចែកចាយ នៅតាមបណ្តាញអ៊ីនធឺណិតក៏ត្រូវមានដែនកំណត់ផងដែរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ញត្តអំពីបញ្ហានេះ ដែលមាត្រា៣១ វាក្យខណ្ឌទី២ បានចែងសេចក្តីថា៖ "...ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់។"

អនុលោមតាមច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់គ្រឹះ បទដ្ឋានគតិយុត្តមួយចំនួនត្រូវបានបង្កើតឡើងដើម្បីចែងលម្អិតទៅលើការកំណត់សិទ្ធិនិងសេរីភាពរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត។

### ២.២.១.ការផ្សព្វផ្សាយក្នុងសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការផ្សព្វផ្សាយក្នុងប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលគ្រប់រូប ចាំបាច់ត្រូវប្រើប្រាស់ព័ត៌មានផ្ទាល់ខ្លួនដូចជា អត្តសញ្ញាណ កំណត់ត្រា ហត្ថលេខាអេឡិចត្រូនិក អាសយដ្ឋានអេឡិចត្រូនិក លេខសម្ងាត់ ឬភិនភាគសម្គាល់ខ្លួន ព្រោះការប្រើប្រាស់ព័ត៌មានរបស់អ្នកដទៃដោយទុច្ចរិត ឬគ្មានការអនុញ្ញាតត្រូវបានហាមឃាត់។[១០]

អន្តរការី ឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវចាត់វិធានការជាបន្ទាន់ ក្នុងករណីដឹងថាព័ត៌មានក្នុងកំណត់ត្រាអាចបង្កឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌ ដូចជាការដកព័ត៌មានចេញពីប្រព័ន្ធ ហើយឈប់ផ្តល់សេវាពាក់ព័ន្ធនឹងព័ត៌មាននោះ រក្សាទុកព័ត៌មានជាភស្តុតាងនិងជូនដំណឹងដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ បន្ថែមពីនេះ ក្នុងករណីបានដឹងអំពីហេតុការណ៍ ឬស្ថានភាពណាមួយដែលអាចបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែកច្បាប់ អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវរក្សាទុកព័ត៌មានជាភស្តុតាងសម្រាប់ជូនជាដំណឹង

[១០] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា២២។

ដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។ លើសពីនេះ បុគ្គលដែលមានចេតនាជូនដំណឹងអំពីសកម្មភាពខុសច្បាប់ ដែលខុសពីការពិត ឬមានលក្ខណៈបោកបញ្ឆោតទៅដល់អន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីឬព្រហ្មទណ្ឌនូវអំពើនោះ(ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩, កថាខណ្ឌទី១ ទី២ និងទី៥ នៃមាត្រា២៥)។

ដើម្បីប្រកបអាជីវកម្ម ឬផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកបាន អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានការអនុញ្ញាត ឬអាជ្ញាបណ្ណ ពីក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាមុនសិន(ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០១៩, កថាខណ្ឌទី១ មាត្រា២៦)។ អ្នកលក់ទំនិញឬសេវាតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ព័ត៌មានដែលត្រឹមត្រូវ ច្បាស់លាស់ និងងាយយល់ដល់អ្នកប្រើប្រាស់។[11]

"បុគ្គលណាក៏ដោយ ទោះបីជាមានទីតាំងអាជីវកម្មក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាដែលផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំទៅកាន់អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជា តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬតាមរយៈអន្តរការី ឬអ្នកផ្តល់សេវាទូរគមនាគមន៍ ត្រូវផ្តល់ជម្រើសច្បាស់លាស់និងងាយស្រួលសម្រាប់ឱ្យអ្នកប្រើប្រាស់អាចបដិសេធមិនទទួលយកទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំនោះ។"[12]

កថាខណ្ឌទី២ មាត្រា៣១ នៃច្បាប់ដដែលនេះ បានដាក់បំរាមបុគ្គលមិនឱ្យបង្កើត ផ្តល់ បង្កលទ្ធភាព ចែកចាយ ឬបញ្ជូនកូដមេរោគចម្លងចូលទៅក្នុងឧបករណ៍ឬប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលដទៃទៀត ដោយបំណងមិនល្អណាមួយឡើយ។

ការចូល ការប្រើប្រាស់ ការកែប្រែ ការបែកធ្លាយ ឬការលាតត្រដាងព័ត៌មានជាលក្ខណៈឯកជនស្ថិតក្នុងទម្រង់អេឡិចត្រូនិកជាសាធារណៈ លុះត្រាតែមានការអនុញ្ញាតពីម្ចាស់នៃព័ត៌មាននោះ ឬពីភាគីផ្សេងទៀតដែលមានការអនុញ្ញាតដោយច្បាប់។ ដូច្នេះ ដើម្បីធានាថាព័ត៌មាននោះមានសុវត្ថិភាពមួយរយភាគរយ បុគ្គលដែលរក្សាព័ត៌មាននោះ ត្រូវប្រើគ្រប់មធ្យោបាយ ឬវិធីសាស្ត្រដើម្បីការពារនូវព័ត៌មាននោះ។ លើសពីនេះ បុគ្គលម្នាក់មិនអាចចូលទៅជ្រៀតជ្រែកក្នុងប្រព័ន្ធអេឡិចត្រូនិករបស់បុគ្គលម្នាក់ទៀត ដោយទុច្ចរិត ឬគ្មានការអនុញ្ញាតពីម្ចាស់ដែលរក្សាទុកព័ត៌មាននោះ ដូចជាការប្រើប្រាស់ ការទាញយក ការថតចម្លង ការស្រង់យក ការធ្វើឱ្យបែកធ្លាយ ការលុបបំបាត់ ឬការកែប្រែទិន្នន័យ ដែលគេរក្សាទុកនោះទេ។[13]

---

[11] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, កថាខណ្ឌទី១ មាត្រា២៩។

[12] ច្បាប់ដដែល, មាត្រា៣០។

[13] ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ០២ វិច្ឆិកា ២០១៩, មាត្រា៣២។

"បុគ្គលណាដែលធ្វើប្រតិបត្តិការប្រព័ន្ធទូទាត់ ផ្តល់សេវាទូទាត់ ចេញផ្សាយឧបករណ៍ទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬផ្តល់មធ្យោបាយទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ឬធ្វើប្រតិបត្តិការណាដែលត្រូវបានចាត់ទុកថាជាការផ្តល់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដល់សាធារណជនត្រូវស្នើសុំការអនុញ្ញាតឬអាជ្ញាបណ្ណជាមុនពីធនាគារជាតិនៃកម្ពុជា។" (ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩, កថាខណ្ឌទី១ មាត្រា៤៦)

លើសពីនេះ កថាខណ្ឌទី៥ មាត្រា៤៧ នៃច្បាប់នេះ បានហាមបុគ្គលគ្រប់រូបមិនឱ្យចេញផ្សាយបណ្ណទូទាត់ ឬកែប្រែបណ្ណទូទាត់ឱ្យខុសពីទម្រង់ដើមដោយគ្មានការអនុញ្ញាត ដែលធ្វើឱ្យមានព្យសនកម្មដល់បុគ្គលម្នាក់ទៀត តាមរយៈទុច្ចរិតភាព ការឆបោក ឬការក្លែងបន្លំ។

### ២.២.២.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌសារព័ត៌មាន

សារព័ត៌មាន គឺមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ប្រាប់ដំណឹង ឬហេតុការណ៍ផ្សេងៗ ដែលកើតឡើងនៅក្នុងសង្គម និងពិភពលោក។ រីឯ អ្នកសារព័ត៌មាន គឺជាតួអង្គដ៏សំខាន់មួយ ជាអ្នកនាំពាក្យពីប្រជាពលរដ្ឋទៅរាជរដ្ឋាភិបាល និងពីរាជរដ្ឋាភិបាលមកប្រជាពលរដ្ឋ ដើម្បីឱ្យដឹងពីបញ្ហា និងរកវិធីដោះស្រាយ ឬធ្វើអន្តរាគមន៍បានទាន់សភាពការណ៍។ កាលពីមុន សារព័ត៌មាន ត្រូវបានផ្សព្វផ្សាយតាមបែបប្រពៃណី ដូចជាកាសែត វិទ្យុ និងទូរទស្សន៍ជាដើម។ ក៏ប៉ុន្តែ នៅសម័យទំនើប សារព័ត៌មាន ដែលលឿនរហ័សទាន់ចិត្ត គឺត្រូវបានផ្សព្វផ្សាយតាមរយៈប្រព័ន្ធអ៊ីនធឺណិត។ ដូច្នេះ ជាការចាំបាច់ណាស់សម្រាប់ក្របខ័ណ្ឌសារព័ត៌មាន ដែលត្រូវសិក្សាឈ្វេងយល់ពីការហាមឃាត់លើការផ្សព្វផ្សាយតាមច្បាប់ស្តីពីរបបសារព័ត៌មាន(ក) និងក្រមសីលធម៌របស់អ្នកសារព័ត៌មាន(ខ)។

#### ក.ការហាមឃាត់លើការផ្សព្វផ្សាយតាមច្បាប់ស្តីពីរបបសារព័ត៌មាន

អ្នកសារព័ត៌មាន មានសិទ្ធិក្នុងការចុះផ្សាយ និងចែករំលែកនូវព័ត៌មាន ដំណឹង អត្ថបទវិភាគ ឬព្រឹត្តិការណ៍សង្គមនានា។ ប៉ុន្តែ ជាអញ្ញត្រកម្មនៃសិទ្ធិចុះផ្សាយ យោងតាមច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ អ្នកសារព័ត៌មាន ត្រូវបានហាមឃាត់នូវការផ្សាយ "...អ្វីដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា។"(មាត្រា១១) ឬ"...ផ្សាយឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ។"(មាត្រា១២) ឬ"...ការជេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ។"(មាត្រា១៣) ឬ"អ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ ជាអាទិ៍: ពាក្យអសុរោះមិនគួរគប្បីដូចជា អា មីង ជាដើម, ពាក្យដែលពិពណ៌នាចំៗអំពីសកម្មភាពរួមរក្ស,រូបគំនូរ ឬរូបថតដែលបង្ហាញនូវកេរ្តិ៍ភេទ ឬរូបអាក្រាត លើកលែងទិសដៅសម្រាប់អប់រំចេញ..."(មាត្រា១៤)។ ចំពោះការផ្សាយ

ពាណិជ្ជកម្ម ដែលខុសពីការពិតទៅលើគុណភាព ឬគុណសម្បត្តិផលិតផល ឬសេវាអ្វីមួយ ដែលនាំឱ្យអ្នកប្រើប្រាស់មានការច្រឡំ ត្រូវបានហាមឃាត់។(មាត្រា១៦)

**ខ.ក្រមសីលធម៌អ្នកសារព័ត៌មាន**

យោងតាមមាត្រា៧ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ សមាគមអ្នកសារព័ត៌មាន ចាំបាច់ត្រូវតាក់តែងក្រមសីលធម៌ សម្រាប់អនុវត្តក្នុងសមាគមរបស់ខ្លួន និងមានកាតព្វកិច្ចគោរពគោលការណ៍ជាចាំបាច់មួយចំនួនដូចជា៖ ត្រូវគោរពសច្ចធម៌, ត្រូវផ្សាយដំណឹងដោយសុចរិត, ធ្វើអត្ថាធិប្បាយឬរិះគន់ឱ្យត្រឹមត្រូវនិងសមស្របតាមគតិយុត្តិធម៌, ត្រូវរាយការណ៍តែព័ត៌មានពិត មានប្រភពច្បាស់លាស់, មិនត្រូវបំបាត់ព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗ, ត្រូវស្វែងរកព័ត៌មាន រូបថត និងឯកសារនានាដោយប្រើវិធីសុចរិតត្រឹមត្រូវ, ត្រូវកែតម្រូវនូវព័ត៌មានណាដែលបានផ្សាយរួចទៅហើយតែមានលក្ខណៈមិនជាក់លាក់និងអាចនាំឱ្យមានការយល់ខុស, ត្រូវចៀសវាងការផ្សព្វផ្សាយព័ត៌មានដែលមានលក្ខណៈញុះញង់ឱ្យប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត, តម្រូវឱ្យមានការគោរពសិទ្ធិនិងសេរីភាពរស់នៅរបស់បុគ្គលឯកជន, ការសរសេរអត្ថបទត្រូវគោរពតាមក្បួនវេយ្យាករណ៍, ហាមផ្សាយអត្ថបទ ឬរូបអាសអាភាស និងការប្រើប្រាស់អំពើហិង្សា, មិនត្រូវរំលោភលើសិទ្ធិដើម្បីមានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗឡើយ។ ហើយក៏ត្រូវបានចាត់ទុកថាជាការរំលោភដ៏ធ្ងន់ធ្ងរខាងវិជ្ជាជីវៈ ក្នុងករណីដែលអ្នកសារព័ត៌មាន ចេញផ្សាយនូវអ្វីដែលជាការលួចគំនិតឬស្នាដៃរបស់អ្នកដទៃ, សរសេរបញ្ឆិតបញ្ឆៀងដើម្បីធ្វើឱ្យគេសង្ស័យដោយអយុត្តិធម៌លើជនណាម្នាក់ ក្រុម ឬបក្សណាមួយ, ការបរិហាកេរ្តិ៍ ជេរប្រមាថ មួលបង្កាច់, ការជំរិតយកប្រាក់ឬទទួលសំណូក ដើម្បីជាថ្នូរនឹងការផ្សាយឬមិនផ្សាយព័ត៌មាន។

**ឧទាហរណ៍**មួយនៃការរំលោភដ៏ធ្ងន់ធ្ងរខាងវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន ហើយនិងឧស្សាហ៍កើតមានជាញឹកញាប់ គឺការចុះផ្សាយនូវព័ត៌មានដែលពាក់ព័ន្ធនឹងអត្តសញ្ញាណរបស់ជនសង្ស័យថា បានប្រព្រឹត្តបទល្មើសណាមួយ ដោយគ្មានការបិទបាំងនូវភិនភាគសម្គាល់ខ្លួន ខណៈដែលជននោះពុំទាន់ត្រូវបានរកឃើញថា មានទោសនៅឡើយ។

### ២.២.៣.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌសុខាភិបាល

ក្នុងក្របខ័ណ្ឌសុខាភិបាល ចំពោះសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតនេះ ការសិក្សាស្រាវជ្រាវសូមលើកអំពីៈ ការផ្សព្វផ្សាយពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា(ក), ការផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ(ខ), ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធឱសថ គ្រឿងសំអាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ(គ), និងការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់(ឃ)។

#### ក.ការផ្សព្វផ្សាយពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

ការផ្សាយពាណិជ្ជកម្មអំពីគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ចាំបាច់ត្រូវតែមានភាពពិតប្រាកដនិងច្បាស់លាស់ មិនត្រូវធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំឡើយ បើពុំដូច្នោះទេ គឺពុំអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឡើយ។ ជាក់ស្តែង មាត្រា២១ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា បានកំណត់ថាៈ "ត្រូវបានហាមឃាត់រាល់ការផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទ ទោះតាមទម្រង់ណាក៏ដោយដែលមានលក្ខណៈភូតកុហក ពង្វាងការពិត ក្លែងបន្លំ ឬធ្វើឱ្យមានការភាន់ច្រឡំអំពីគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវាដែលទាក់ទិនទៅនឹងៈ ប្រសិទ្ធភាពមុខនាទីអត្តសញ្ញាណ យថាប្រភេទ ប្រភេទ ប្រភព គុណភាពខាងរូបធាតុ ឬខាងទ្រទ្រង់រាងកាយ ធាតុផ្សំ បរិមាណ របៀបនិងកាលបរិច្ឆេទនៃការផលិត កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ វិធី និងល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ របៀបនៃការលក់ អត្ថិភាព តម្លៃ និងការធានាអះអាងផ្សេងៗទៀតដែលបានសន្យា។"

#### ខ.ការផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ

ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ គឺត្រូវបានកំណត់ ដើម្បីការពារទារកនិងកុមារ។ ទារក ត្រូវបានកំណត់អាយុត្រឹម១២ខែ និងកុមារអាយុ ២៤ខែ។[១៤] ផលិតករ ឬអ្នកចែកចាយទាំងឡាយមិនត្រូវធ្វើការផ្សព្វផ្សាយលើកកម្ពស់ការប្រើប្រាស់ផលិតផលចិញ្ចឹមទារកនិងកុមារតូចៗ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ដោយខ្លួនឯងឬតាមរយៈអ្នកតំណាងរបស់ខ្លួនបានឡើយ ដែលរូបភាពផ្សព្វផ្សាយលើកកម្ពស់ទាំងនោះមានដូចជា ការឃោសនាពាណិជ្ជកម្ម ការប្រើល្បិចកលលើការលក់ផលិតផល ការបរិច្ចាគឬចែកចាយសម្ភារៈឯកសារព័ត៌មាន ឬឯកសារអប់រំពីរបៀបនៃការចិញ្ចឹម ឬការអនុវត្តមុខងារអប់រំទាក់ទិននឹងការចិញ្ចឹមទារកនិងកុមារតូចៗ។[១៥]

---

[១៤]អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ, លេខ ១៣៣ អនក្រ/បក, ១៨វិច្ឆិកា ២០០៥, មាត្រា២។

[១៥] អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ, លេខ ១៣៣ អនក្រ/បក, ១៨វិច្ឆិកា២០០៥, មាត្រា១៣។

**គ.ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធឱសថ គ្រឿងសំអាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ**

ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធឱសថបូរាណ ឱសថសម័យ គ្រឿងសំអាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាពាក់ព័ន្ធនឹងវិស័យវេជ្ជសាស្ត្រ ចាំបាច់ត្រូវមានទិដ្ឋាការពីក្រសួងសុខាភិបាល។ យោងតាមប្រកាសរួមក្រសួងសុខាភិបាល និងក្រសួងព័ត៌មាន ស្ដីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ គ្រឿងសំអាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ត្រង់ប្រការ១ បានចែងថា៖ "ការផ្សព្វផ្សាយពាណិជ្ជកម្ម ឱសថបូរាណ ឱសថសម័យ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ(បន្ទប់ពិគ្រោះជំងឺ មន្ទីរសម្រាកព្យាបាល មន្ទីរពហុព្យាបាល មន្ទីរពិសោធន៍ មន្ទីរសម្ភព មន្ទីរព្យាបាលមាត់ធ្មេញ មន្ទីរសោភ័ណសល្យសាស្ត្រ និងកែសម្ផស្ស) តាមរយៈទូរទស្សន៍ វិទ្យុ សារព័ត៌មាន ទស្សនាវដ្ដី ព្រឹត្តប័ត្រ និងការឃោសនាព័ត៌មានតាមសកម្មភាពផ្សេងៗអាចធ្វើទៅបាន៖ ក.លុះត្រាតែម្ចាស់សេវា ដែលត្រូវការឃោសនាពាណិជ្ជកម្មនោះ ទទួលបានការអនុញ្ញាត(ទិដ្ឋាការ) ពីក្រសួងសុខាភិបាល បន្ទាប់ពីមានការឯកភាពគ្នានូវខ្លឹមសារអត្ថបទ ស្ពតវីដេអូឬការសែតសោតទស្សន៍ និងរូបភាពដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្ម។ ខ.ការផ្សព្វផ្សាយពាណិជ្ជកម្មត្រូវបានបញ្ឈប់ ឬត្រូវដកហូតវិញនូវលិខិតអនុញ្ញាត(ទិដ្ឋាការ) ក្នុងករណីក្រសួងសុខាភិបាលពិនិត្យឃើញថា ខ្លឹមសារអត្ថបទ និងរូបភាពដែលត្រូវផ្សាយមានលក្ខណៈខុសផ្ទុយពីការអនុញ្ញាត ឬគ្មានទិដ្ឋាការអនុញ្ញាត ហើយធ្វើលិខិតលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ឱ្យច្បាស់ពីអត្តសញ្ញាណស្ថានីយ៍វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ឬព្រឹត្តិប័ត្រណាមួយ ដែលកំពុងផ្សព្វផ្សាយពាណិជ្ជកម្មបែបនេះទៅក្រសួងព័ត៌មាន ដើម្បីស្នើសុំកិច្ចសហការចាត់វិធានការជាបន្ទាន់។"[១៦]

បន្ថែមពីនេះទៀត យោងតាមប្រការ២ នៃប្រកាសនេះ បានបញ្ញត្តថា៖ "សហគ្រាស ឬសេវាឯកជន សាមីជន មិនអាចសុំធ្វើការផ្សាយពាណិជ្ជកម្មឱសថសម័យ-បូរាណ ទោះបីតាមមធ្យោបាយណាមួយបានទេ ចំពោះឱសថដែលផ្សំឡើងដោយសារធាតុមានគ្រោះថ្នាក់(ដែលលក់ត្រូវមានវេជ្ជបញ្ជា) ដូចជាឱសថញៀន ឱសថប្រព័ន្ធសរសៃប្រសាទ ឱសថពន្លូតកូន ឱសថព្យាបាលជំងឺកាមរោគ ឱសថព្យាបាលជំងឺអេដស៍ ឱសថព្យាបាលជំងឺមហារីក ឱសថបង្កើនតណ្ហា ឱសថប្រើសម្រាប់ទារក...។ល។ និង។ល។"

ទន្ទឹមនឹងនេះដែរ ប្រកាសដដែលបានផ្ដល់ឱ្យក្រសួងព័ត៌មានមានអំណាចក្នុងការបដិសេធមិនអនុញ្ញាតឱ្យផ្សាយ ឬបញ្ឈប់ភ្លាមនូវការផ្សព្វផ្សាយពាណិជ្ជកម្មឱសថ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងវេជ្ជសាស្ត្រ ដែលប៉ះពាល់ដល់វប្បធម៌ប្រពៃណីខ្មែរ និងសង្គមជាតិ។ ក្នុងករណីដែលបានរកឃើញថា មានការផ្សព្វផ្សាយដែលបំផ្លើសពីគុណភាពឱសថ គ្រឿងសំអាង ក្រសួងសុខាភិបាល អាចស្នើមកក្រសួងព័ត៌មានដើម្បី

[១៦] ប្រកាសរួមស្ដីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ, លេខ ៧៥/០៦ ពម/ប្រក របស់ក្រសួងព័ត៌មាន និង លេខ ០០៧ អនស/ម/ព របស់ក្រសួងសុខាភិបាល, ២១ កុម្ភៈ ២០០៦, ប្រការ១។

បញ្ឈប់នូវសកម្មភាពល្មើសច្បាប់ទាំងនោះ។[១៧]

**ករណីជាក់ស្តែងមួយ៖** ក្រសួងសុខាភិបាល បានរកឃើញគណនីហ្វេសប៊ុកឈ្មោះ ChoA Cosmetics **បោះដុំផលិតផលកូរ៉េ** បានធ្វើការផ្សព្វផ្សាយលក់គ្រឿងសម្អាងគ្មានលេខប្រវេទន៍ និងគ្មានការទទួលស្គាល់ពីក្រសួងសុខាភិបាល។ ដូច្នេះ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ក្រសួងសុខាភិបាល បានចេញសេចក្តីជូនដំណឹងដើម្បីហាមឃាត់គណនីហ្វេសប៊ុកខាងលើនេះ និងជូនព័ត៌មានដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបញ្ឈប់ការប្រើប្រាស់ផលិតផលទាំងនេះជាបន្ទាន់ ដើម្បីចៀសវាងការខាតបង់ប្រាក់កាស និងប៉ះពាល់ដល់សុខភាព ឬឈានដល់បាត់បង់ជីវិតរបស់អ្នកប្រើប្រាស់។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ថ្ងៃ... ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០២០

សេចក្តីជូនដំណឹង
ស្តីពីការហាមឃាត់គណនីបណ្តាញសង្គមហ្វេសប៊ុកឈ្មោះ ChoA Cosmetics បោះដុំផលិតផលកូរ៉េសុទ្ធ កំពុងផ្សព្វផ្សាយលក់ផលិតផលគ្រឿងសម្អាងគ្មានលេខប្រវេទន៍ និង គ្មានការទទួលស្គាល់ពីក្រសួងសុខាភិបាល

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនដល់សាធារណជនទាំងអស់ឲ្យបានជ្រាបថា តាមរយៈការតាមដានត្រួតពិនិត្យឃើញលើបណ្តាញសង្គមហ្វេសប៊ុក (Facebook) មានគណនីឈ្មោះ ChoA Cosmetics បោះដុំផលិតផលកូរ៉េសុទ្ធ កំពុងផ្សព្វផ្សាយលក់ផលិតផលគ្រឿងសម្អាងមួយចំនួនដោយគ្មានលេខប្រវេទន៍ និងគ្មានច្បាប់អនុញ្ញាតឲ្យផ្សព្វផ្សាយពីក្រសួងសុខាភិបាលឡើយមានដូចជា៖ ១.Laneige Water Sleeping Mask New, ២. Snail Truecica , ៣. Aloevera Moisture Sootong Gel, ៤.Saryeoni Cleasing Foam, និងផលិតផលគ្រឿងសម្អាងផ្សេងៗជាច្រើនទៀត។

អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ និងច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការគ្រប់គ្រងឱសថ តម្រូវឲ្យរាល់ការចែកចាយគ្រឿងសម្អាងគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខប្រវេទន៍ពីក្រសួងសុខាភិបាល ហើយរាល់ការផ្សព្វផ្សាយផលិតផលទាំងនេះត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល។

ដើម្បីចៀសវាងការខាតបង់ប្រាក់កាស និងប៉ះពាល់ដល់សុខភាព ឬឈានដល់បាត់បង់ជីវិតរបស់អ្នកប្រើប្រាស់ទៀតនោះ ក្រសួងសុខាភិបាលសូមជូនព័ត៌មានដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបញ្ឈប់ការប្រើប្រាស់ផលិតផលទាំងនេះជាបន្ទាន់ ។

ក្រសួងសុខាភិបាលនឹងមានវិធានការតឹងរ៉ឹងទៅតាមផ្លូវច្បាប់ចំពោះម្ចាស់គណនីហ្វេសប៊ុកឈ្មោះ ChoA Cosmetics បោះដុំផលិតផលកូរ៉េសុទ្ធ ដែលកំពុងផ្សព្វផ្សាយលក់ផលិតផលគ្រឿងសម្អាងទាំងនេះទៅតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថជាធរមាន។

ក្នុងករណីបងប្អូនត្រូវការព័ត៌មានបន្ថែមពីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាល សូមទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ៖ ០១១ ៨៣៦ ៣៨៣,០១២ ៩៨៣ ៣៣៦,០១២ ៨៩២ ០៦៦ , ០១៣ ២០២ ២៣០, ០១២ ៥៦៦ ៦៦២, ០១៣ ៨៦៦ ៣២០ ។

សូមភ្ជាប់មកជាមួយនូវរូបភាពគណនីហ្វេសប៊ុកឈ្មោះ ChoA Cosmetics ... កូរ៉េសុទ្ធ និងផលិតផលគ្រឿងសម្អាងខុសច្បាប់ ។

ប្រភព៖ https://www.facebook.com/MinistryofHealthofCambodia/posts/3002119516493801

រូបភាពទី ២.១៖ សេចក្តីជូនដំណឹងស្តីពីការហាមឃាត់ការផ្សព្វផ្សាយលក់ផលិតផលគ្រឿងសំអាងគ្មានលេខប្រវេទន៍

[១៧] ប្រកាសរួមស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបុរាណ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារកថ្មីដក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ, លេខ ៧៥/០៦ ពម/ប្រក របស់ក្រសួងព័ត៌មាន និងលេខ ០០៧ អនស/ម/ព របស់ក្រសួងសុខាភិបាល, ២១ កុម្ភៈ ២០០៦, ប្រការ៣។

**ឃ.ការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់**

ថ្នាំជក់ ឬបារី បានឆក់យកជីវិតមនុស្សជារៀងរាល់ឆ្នាំ។ ការប្រើប្រាស់ថ្នាំជក់ អាចបណ្តាលឱ្យប៉ះពាល់ដល់សុខភាព។ មានជំងឺមួយចំនួនបង្កឡើងដោយការប្រើប្រាស់ថ្នាំជក់ ដែលមានដូចជា ជំងឺបេះដូង ជំងឺសរសៃឈាមខួរក្បាល សរសៃឈាមបេះដូង និងជំងឺទើ្លងឈាមជាដើម។ ហេតុនេះហើយ រាល់ការផ្សព្វផ្សាយផលិតផលថ្នាំជក់ ត្រូវបានរដ្ឋដាក់កំហិតហាមឃាត់។ មាត្រា៥ នៃអនុក្រឹត្យលេខ ៣៥ អនក្រ/បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ បាននិយាយលម្អិតអំពីការផ្សព្វផ្សាយផលិតផលថ្នាំជក់ ដែលមានអត្ថន័យថា៖ "ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ស៊ីឌី វីស៊ីឌី ឌីវីឌី និងតាមសេវាទូរគមនាគមន៍ផ្សេងៗទៀត ត្រូវហាមឃាត់។"

បន្ថែមលើនេះ កថាខណ្ឌទី១ មាត្រា៦ នៃអនុក្រឹត្យដដែល បានកំណត់ថា៖ "ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយផលិតផលថ្នាំជក់ផ្សេងៗទៀតជាសាធារណៈ...ត្រូវហាមឃាត់។..." រាល់ការផ្សព្វផ្សាយផលិតផលថ្នាំជក់នៅទីសាធារណៈតាមរយៈកម្មវិធីផ្សេងៗ ដូចជាកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីកីឡាជាដើម មិនត្រូវបានអនុញ្ញាតឡើយ។[១៨] ការឧបត្ថម្ភជាផលិតផលថ្នាំជក់ ឬសម្ភារៈដែលមានឈ្មោះផលិតផលថ្នាំជក់ ក្នុងកម្មវិធីដែលផ្សាយជាសាធារណៈ ត្រូវបានហាមឃាត់។[១៩] ក្រសួងសុខាភិបាល ជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការណែនាំនិងត្រួតពិនិត្យលើការផ្សព្វផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់(អនុក្រឹត្យស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ ឆ្នាំ២០១១, មាត្រា៤)។

**២.២.៤.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌកម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ**

ការផ្សព្វផ្សាយ ឬការចែកចាយនៅលើប្រព័ន្ធអ៊ីនធឺណិតទាំងឡាយ គឺមិនត្រូវប៉ះពាល់ដល់កម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធឡើយ។ សិទ្ធិអ្នកនិពន្ធ គឺសំដៅសិទ្ធិលើស្នាដៃអក្សរសាស្ត្រ និងសិល្បៈទាំងឡាយ ដូចជារឿងប្រលោមលោក កំណាព្យ និងល្ខោន ភាពយន្ត ស្នាដៃតន្ត្រី គំនូរ រូបថត ចម្លាក់ និងស្ថាបត្យកម្មជាដើម[២០]។ រាល់ស្នាដៃទាំងអស់នេះ ត្រូវទទួលបានកិច្ចការពារពីច្បាប់ដោយស្វ័យប្រវត្តិ[២១] ទោះបីជាស្នាដៃនោះបានចុះបញ្ជី ឬពុំបានចុះបញ្ជីក៏ដោយ។ ដើម្បីឱ្យស្នាដៃមួយអាចទទួលបានការការពារពីច្បាប់នេះបាន ល្គឹកណា ស្នាដៃនោះ

[១៨] អនុក្រឹត្យស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់,លេខ ៣៥ អនក្រ/បក, ២៤ កុម្ភៈ ២០១១, មាត្រា៧។

[១៩] អនុក្រឹត្យដដែល, មាត្រា៨។

[២០] យោងតាមគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម, https://www.cambodiaip.gov.kh/, បានចូលពិគ្រោះនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០។

[២១] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣, មាត្រា៣៨។

ស្ថិតនៅជាទម្រង់ជាក់លាក់ណាមួយ ពុំមែននៅជាគំនិតអរូបិយ[២២] និងជាស្នាដៃដើមដែលពុំចម្លងគេ។ ដើម្បីអាចចាត់ទុកថាជាស្នាដៃដើមបាន កាលណាស្នាដៃនោះត្រូវបានបង្កើតឡើងតាមគំនិតប្រាជ្ញាផ្ទាល់ខ្លួនរបស់អ្នកបង្កើតស្នាដៃនោះ។[២៣] ស្នាដៃមួយដែលនិពន្ធពុំទាន់ចប់ ឬពុំទាន់បានផ្សាយជាសាធារណៈក្តី ត្រូវចាត់ទុកថាបានបង្កើតឡើងដោយចំណេះដឹងពិតតែមួយគត់របស់អ្នកនិពន្ធ។[២៤]

**ក.ប្រភេទស្នាដៃដែលទទួលបានការការពារ**

យោងតាមមាត្រា៣ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ បានកំណត់អត្ថន័យនៃពាក្យស្នាដៃថា "ជាផលិតផលខាងវិស័យអក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី ដែលកើតចេញពីការច្នៃប្រឌិតបង្កើតឡើង ដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា។" ចំពោះស្នាដៃដែលត្រូវទទួលបានការការពារយោងតាមមាត្រា៧ នៃច្បាប់នេះ មានដូចខាងក្រោម៖

- សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀត ស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ
- អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀតដែល មានប្រភេទដូចគ្នា
- ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី
- ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណឬប្រពៃណី
- ការសម្តែងសៀកនិងការសម្តែងកាយវិការ
- ការតែងបទភ្លេងដោយមានឬគ្មានទំនុកច្រៀង
- ស្នាដៃសោតទស្សន៍
- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូប ឬសិល្បៈអនុវត្ត
- ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នានឹងការថតរូប
- ស្នាដៃស្ថាបត្យកម្ម
- ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូបដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រ
- កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធានដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ
- ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ។

[២២] សេង ឌីណា, *ការក្សាសិទ្ធិ៖ តើអ្នកនិពន្ធស្នាដៃទទួលបានការការពារបែបណាខ្លះ?*, ចុះផ្សាយដោយ វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១១ ម៉ោង១២:១៧ ,https://www.rfi.fr/km/copyright-law , បានចូលពិគ្រោះនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០។

[២៣] ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៤, ០៥ មីនា ២០០៣, មាត្រា៤។

[២៤] ច្បាប់ដដែល, មាត្រា៥។

ស្នាដៃបន្ត ដែលមានចែងក្នុងមាត្រា៨ នៃច្បាប់នេះ រួមមាន "ការបកប្រែ ការយកលំនាំតាម ការសម្រួល ការកែច្នៃ ឬការកែលំអស្នាដៃផ្សេងៗទៀត...។" និងសេចក្តីដូចមានចែងក្នុងមាត្រា៩ នៃច្បាប់ដដែល គឺ "ចំណងជើងនៃស្នាដៃណាមួយដែលបង្ហាញពីលក្ខណៈស្នូលនៃស្នាដៃដើម ចំណងជើងនោះត្រូវទទួលបាននូវកិច្ចការពារពីច្បាប់ដូចគ្នានឹងស្នាដៃនោះដែរ។"

**ខ.ស្នាដៃដែលមិនទទួលបាននូវការការពារ**

យោងតាមមាត្រា១០ នៃច្បាប់ដដែលនេះ មានដូចជា៖

- រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានផ្លូវការនានា
- ប្រកាស សេចក្តីសម្រេច លិខិតបញ្ជាក់ សារាចរណែនាំផ្សេងៗដែលចេញដោយអង្គការរដ្ឋ
- សេចក្តីសម្រេច សាលក្រម ឬសាលដីកាផ្សេងៗរបស់តុលាការ
- អត្ថបទបកប្រែជាភាសាបរទេស នៃចំណុចទ្រទី១ ទី២ និងទី៣ខាងលើ
- គំនិត នីតិវិធី ប្រព័ន្ធ របៀបប្រតិបត្តិការ ទស្សនៈ គោលការណ៍ ការរុករកឃើញឬទិន្នន័យសាមញ្ញ ទោះបីត្រូវបានផ្សព្វផ្សាយ អត្ថាធិប្បាយ ពន្យល់ឬមានក្នុងស្នាដៃណាមួយក៏ដោយ។

**គ.ការរំលោភសិទ្ធិលើការផ្សព្វផ្សាយដែលប៉ះពាល់ដល់កម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ**

សព្វថ្ងៃ សកម្មភាពនៅតាមអ៊ីនធឺណិត បាននិងកំពុងតែរីកសុះសាយ។ អ៊ីនធឺណិតបានក្លាយជាមធ្យោបាយដ៏រហ័សទាន់ចិត្ត សម្រាប់ធ្វើការផ្សព្វផ្សាយ ការចែកចាយព័ត៌មាន ការបញ្ចេញមតិ ការកម្សាន្ត និងជាពិសេសទៀតនោះ គឺការទាញផលប្រយោជន៍ខាងសេដ្ឋកិច្ចនៅលើបណ្តាញទំនាក់ទំនងសង្គម។ ជាក់ស្តែង និងកំពុងពេញនិយមផងនោះ បុគ្គលមួយចំនួនបានប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមដូចជា Youtube ឬ Facebook ជាដើម ដើម្បីដាក់បង្ហោះ ផ្សព្វផ្សាយជាសាធារណៈ(Public) នូវវីដេអូខ្លីៗពាក់ព័ន្ធនឹងការកម្សាន្ត ការអប់រំ ចំណេះដឹងទូទៅ និងទស្សនីយភាពផ្សេងៗ ក្នុងផលប្រយោជន៍ឯកជន ពុំមែនប្រយោជន៍សាធារណៈ ដើម្បីទាក់ទាញចំណាប់អារម្មណ៍ទស្សនិកជនឱ្យចូលមើល(Views) ចុចចូលចិត្ត(Like) និងបញ្ចេញមតិ(Comment) កាន់តែច្រើន ដើម្បីទាញទឹកចិត្តក្រុមហ៊ុនឯកជននានា ឱ្យមកដាក់ផ្សព្វផ្សាយពាណិជ្ជកម្ម និងគោលបំណងចុងក្រោយរបស់អ្នកផ្សព្វផ្សាយនោះ គឺចង់បានប្រាក់កម្រៃពីម្ចាស់ក្រុមហ៊ុន Youtube និង Facebook។ ជារឿងម្យ៉ាងដែលបុគ្គលខិតខំរៀនសូត្រចេះដឹងអំពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត និងចេះទាញរកប្រាក់ចំណូល ប៉ុន្តែមានបុគ្គលមួយចំនួនក៏បានរំលោភបំពានលើកម្មសិទ្ធិបញ្ញារបស់អ្នកដទៃដើម្បីធ្វើរឿងនេះ។ ដូច្នេះ រាល់ការផ្សព្វផ្សាយទាំងឡាយតាមប្រព័ន្ធអ៊ីនធឺណិត ដែលប៉ះពាល់ដល់កម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ គឺច្បាប់ពុំបានអនុញ្ញាតទេ។ យោងតាមមាត្រា២១ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣ គឺអ្នកនិពន្ធមានសិទ្ធិខាងបេតិកភណ្ឌ ឬអាចហៅម្យ៉ាងទៀតថា សិទ្ធិខាងសេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យអ្នកនិពន្ធមានសិទ្ធិប្រកបអាជីវកម្មលើទ្រព្យជាស្នាដៃរបស់ខ្លួន តាមរយៈការផលិតឡើងវិញ ការផ្សព្វផ្សាយជាសាធារណៈ និងការបង្កើត

ស្នាដៃបន្ត។ តាមស្មារតីនៃច្បាប់ ត្រង់មាត្រានេះ គឺបានបង្កប់អត្ថន័យនៃការផ្សព្វផ្សាយជាសាធារណៈ ដោយបញ្ចូលទាំងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។ នេះមានន័យថា ប្រសិនបើបុគ្គល បានប្រើប្រាស់ ចម្លងទាំងស្រុងឬដោយផ្នែក ឬផលិតឡើងវិញនូវស្នាដៃទាំងឡាយ(ដូចមានចែងនៅក្នុងមាត្រា៧ មាត្រា៨ និង មាត្រា៩ ដែលបានបញ្ជាក់នៅទំព័រខាងលើ) ដោយគ្មានការអនុញ្ញាតពីម្ចាស់ស្នាដៃ ឬម្ចាស់កម្មសិទ្ធិ ក្នុងគោលបំណងដើម្បីបម្រើផលប្រយោជន៍ឯកជន ឬស្វែងរកផលប្រយោជន៍ខាងសេដ្ឋកិច្ច ពុំមែនជាប្រយោជន៍នៃការអប់រំមិនបង់ប្រាក់កម្រៃ[២៥]ឬប្រយោជន៍ប្រជាពលរដ្ឋទូទៅ ដោយយកស្នាដៃទាំងនោះ ទៅធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើប្រព័ន្ធអ៊ីនធឺណិត គឺជាការរំលោភកម្មសិទ្ធិបញ្ញាលើស្នាដៃ ដែលច្បាប់បានហាម។ ទោះបីជាការផ្សព្វផ្សាយដែលមានការយល់ព្រមពីម្ចាស់ស្នាដៃ ឬម្ចាស់កម្មសិទ្ធិរួចទៅហើយក្តី ប៉ុន្តែពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រភពនិងឈ្មោះម្ចាស់ស្នាដៃ[២៦]គឺជាការរំលោភលើសិទ្ធិខាងសីលធម៌របស់អ្នកនិពន្ធ។ ជាដើម ដូចជា ការចម្លងអត្ថបទ រូបភាពពីគេហទំព័រមួយទៅដាក់ក្នុងគេហទំព័រផ្សេងទៀត ដោយគ្មានការអនុញ្ញាតពីម្ចាស់ស្នាដៃ និងគ្មានបញ្ជាក់ពីប្រភពនិងឈ្មោះម្ចាស់ស្នាដៃ។

**ករណីជាក់ស្តែង** ដែលបានកើតឡើងពាក់ព័ន្ធនឹងការរំលោភបំពានកម្មសិទ្ធិបញ្ញានៃបទចម្រៀងពីដើម។ មានអ្នកចម្រៀងជាច្រើនរូបរួចមកហើយ ដែលបានយកបទចម្រៀងមរតកដើមមកផលិត និងច្រៀងឡើងវិញ(Cover) ដោយគ្មានការអនុញ្ញាតពីម្ចាស់នៃកម្មសិទ្ធិបញ្ញា មិនតែប៉ុណ្ណោះ ថែមទាំងធ្វើការកែចំណងជើង ឬខ្លឹមសារ ដែលធ្វើឱ្យខូចទម្រង់ដើម ហើយបង្ហោះតាមបណ្តាញសង្គមនានាដូចជា Facebook និង Youtube។ ហេតុដូច្នេះ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានចេញសេចក្តីប្រកាសព័ត៌មានមួយស្តីពីការរំលោភបំពានស្នាដៃអក្សរសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី គ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍ ដើម្បីជាការជូនដំណឹងដល់បុគ្គលគ្រប់មជ្ឈដ្ឋានទាំងអស់ ឱ្យបញ្ឈប់នូវសកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញានេះជាបន្ទាន់។ ករណីនៅតែរំលោភបំពាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នឹងចាត់វិធានការតាមផ្លូវច្បាប់។

---

[២៥] សូមពិគ្រោះ មាត្រា២៥ ចំណុច គ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។

[២៦] សូមពិគ្រោះ មាត្រា២០ ចំណុច ខ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ឆ្នាំ២០០៣។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការរំលោភបំពានស្នាដៃអក្សរសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី**
**គ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍**

ទោះបីកន្លងមកក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានពន្យល់ណែនាំ និងផ្សព្វផ្សាយច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល" ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ជាច្រើនលើកច្រើនដងក៏ដោយ ក្រសួងនៅតែសង្កេតឃើញថា បណ្តាអង្គភាពខ្សែផ្សាយ ក្រុមហ៊ុនផលិតកម្ម និងបុគ្គលមួយចំនួនទាំងនៅក្នុងនិងក្រៅប្រទេសបាននិងកំពុងប្រើប្រាស់ស្នាដៃអក្សរសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រីគ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍ដើម្បីយកទៅផលិតឡើងវិញ សម្តែងឡើងវិញ ថតបញ្ចូលទៅជាសោតទស្សន៍ ហើយបង្ហោះតាមបណ្តាញសង្គមនានាដូចជា Facebook និង YouTube ដោយពុំមានការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ (មាត្រា៣៣)។ មិនតែប៉ុណ្ណោះថែមទាំងបានកែប្រែចំណងជើង ឬខ្លឹមសារដែលធ្វើឱ្យខូចទម្រង់នៃស្នាដៃដើម អាចនឹងនាំឱ្យមហាជនមានការភាន់ច្រឡំ។ ទង្វើទាំងនេះ គឺជា**ការរំលោភបំពានលើសិទ្ធិសីលធម៌និងសិទ្ធិសេដ្ឋកិច្ចរបស់អ្នកនិពន្ធ** ដូចមានចែងក្នុង មាត្រា៩ មាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២២ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមជម្រាបមកអ្នកនិពន្ធ ផលិតករភាពយន្ត វីដេអូ ផលិតករហ្វុណូក្រាម អង្គភាពខ្សែផ្សាយ(វិទ្យុ ទូរទស្សន៍) សិល្បករ សិល្បការិនី បណ្តាក្រុមហ៊ុនផលិតកម្ម និងបុគ្គលមួយចំនួនទាំងនៅក្នុងនិងក្រៅប្រទេស ដែលបានយកស្នាដៃគ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍ ទៅផលិតឡើងវិញ សម្តែងឡើងវិញ ថតបញ្ចូលទៅជាសោតទស្សន៍ ដើម្បីចែកផ្សាយនិងផ្សព្វផ្សាយតាមប្រព័ន្ធខ្សែផ្សាយនិងបណ្តាញសង្គមនានាដោយពុំមានការអនុញ្ញាតពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ **គឺជាអំពើខុសច្បាប់**។ ប្រការនេះ អ្នកនិពន្ធ ម្ចាស់អង្គភាពខ្សែផ្សាយ ក្រុមហ៊ុនផលិតកម្ម ផលិតករ សិល្បករ សិល្បការិនី និងបុគ្គលមួយចំនួន ត្រូវបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពរំលោភបំពានខាងលើ ដើម្បីចូលរួមគោរពច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល" ទាំងអស់គ្នា។

ក្នុងករណីនៅតែរំលោភបំពាន ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនឹងចាត់វិធានការតាមផ្លូវច្បាប់។ ការចាត់វិធានការនានាជាយថាហេតុ គឺក្នុងបំណងការពារនិងលើកស្ទួយស្នាដៃដើម និងការបង្កើតស្នាដៃថ្មីៗខាងវិស័យវប្បធម៌ ដែលជាផ្នែកមួយក្នុងការជំរុញឧស្សាហកម្មវប្បធម៌នៅកម្ពុជាឱ្យមានការរីកចម្រើន។

ថ្ងៃ ព្រហស្បតិ៍ ១២ កើត ខែមាឃ ឆ្នាំកុរ ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ប្រភព៖ https://kohsantepheapdaily.com.kh/article/1035322.html

រូបភាពទី ២.២៖ សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ស្តីពីការរំលោភបំពានស្នាដៃអក្សរសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី គ្មានអ្នកទទួលមរតកឬគ្មានមរតកសាសន៍

### ២.២.៥.ការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវប្បធម៌ជាតិ

វប្បធម៌ គឺជាអត្តសញ្ញាណជាតិ ជាគ្រឿងសម្រាប់សម្គាល់ជាតិសាសន៍នីមួយៗ។ ទោះបីជា សង្គមជាតិមួយមានការរីកចម្រើន និង ដើរដល់យុគសម័យកុំព្យូទ័រនិងអ៊ីនធឺណិតយ៉ាងណាក៏ដោយ ក៏គេមិនបំបាត់ចោលវប្បធម៌របស់ជាតិខ្លួនឡើយ។ សង្គមមួយដែលទទួលយកវប្បធម៌របស់អ្នកដទៃ ដោយលះបង់នូវវប្បធម៌របស់ខ្លួន នោះនឹងធ្វើឱ្យជាតិសាសន៍ខ្លួន ឈានទៅរកការបាត់បង់អត្តសញ្ញាណជាក់ជាមិនខាន។ ដូចសុភាសិតមួយលើកឡើងថា «វប្បធម៌រលត់ ជាតិរលាយ វប្បធម៌ពណ្ណរាយ ជាតិថ្កើងថ្កាន»។ នេះមានន័យថា វប្បធម៌ គឺស្មើនឹងជាតិ។ ហេតុនេះហើយ ទើបបានជាតម្រូវឱ្យមានការយកចិត្តទុកដាក់ក្នុងការការពារវប្បធម៌ជាតិ។

យ៉ាងណាមិញ ដោយសារតែមធ្យោបាយនៃការផ្សព្វផ្សាយមានភាពជឿនលឿន រហ័ស និងងាយស្រួលតាមរយៈប្រព័ន្ធអ៊ីនធឺណិត ដោយក្នុងនោះ ការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមដូចជា Facebook, Youtube, Instagram ជាដើម គឺកំពុងមានការពេញនិយមខ្លាំង។ ការផ្សព្វផ្សាយមួយចំនួនបានធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណីល្អរបស់សង្គមជាតិ ដែលការណ៍នេះ ធ្វើឱ្យក្រសួង-ស្ថាប័នមានសមត្ថកិច្ច ត្រូវតែដាក់ចេញនូវវិធានការ ទប់ស្កាត់ ការពារជាចាំបាច់។

#### ក.ការហាមឃាត់ចំពោះការផ្សព្វផ្សាយដែលប៉ះពាល់វប្បធម៌ជាតិ

រាល់ការផ្សព្វផ្សាយ ឬការចែកចាយតាមរយៈប្រព័ន្ធអ៊ីនធឺណិតទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ជាតិ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានដាក់ចេញនូវវិធានការក៏ដូចជាបំរាមលើសកម្មភាពផ្សព្វផ្សាយមួយចំនួនផងដែរ។ ជាក់ស្តែងដូចជា សេចក្តីណែនាំលេខ០៣ សណន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ ស្តីពីវិធានការទប់ស្កាត់ការផ្សព្វផ្សាយ ឬការចែកចាយខ្លឹមសារព័ត៌មាន សារជាអក្សរ សំឡេង រូបភាព វីដេអូ និងទម្រង់ផ្សេងៗ ដែលបណ្តាលឱ្យមានផលប៉ះពាល់ចំពោះវប្បធម៌ទំនៀមទម្លាប់ប្រពៃណីជាតិ។ សេចក្តីណែនាំនេះមានខ្លឹមសារជាការណែនាំ និងដាក់កំហិតដល់អ្នកប្រើប្រាស់គេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមមួយចំនួន ជាពិសេសអាជីវកម្មតាមប្រព័ន្ធអនឡាញ អ្នកនិពន្ធបទភ្លេង ទំនុកច្រៀង និងអ្នកសម្តែងក្រៅប្រព័ន្ធទាំងឡាយ សូមឱ្យបញ្ឈប់នូវការផ្សព្វផ្សាយគ្រប់រូបភាព សារជាអក្សរ/សំឡេង និងវីដេអូ ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពរបស់សង្គមជាតិ។

ក្នុងករណីដែលបុគ្គល ឬក្រុមណាមួយ នៅបន្តប្រព្រឹត្តសកម្មភាពអវិជ្ជមានខាងលើ ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ[២៧] នឹងសហការជាមួយក្រសួងមហាផ្ទៃ ឬ/និង ក្រសួងព័ត៌មាន ឬ/និង ក្រសួងប្រៃសណីយ៍និង

[២៧] **ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ** ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ២៧ សសរ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីពិនិត្យ វាយតម្លៃ និងសម្រេចការដាក់ពិន័យ ឬផ្តល់ការលើកសរសើរ ចំពោះសកម្មភាពសិល្បៈ ប្រពៃណី ទំនៀមទម្លាប់ និងសីលធម៌សង្គម ដែលបានលើកស្ទួយអត្តសញ្ញាណវប្បធម៌ សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពជាតិខ្មែរ។

ទូរគមនាគមន៍ ឬ/និង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការតាមក្រមសីលធម៌នៃអ្នកសិល្បៈ ឬ/និង ប្រកាសអន្តរក្រសួងលេខ១៧០ ប្រក.អន្តរក្រ. ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា ឬ/និង ដាក់បណ្តឹងទៅតុលាការ ដោយអនុលោមតាមក្រមព្រហ្មទណ្ឌ ឬ/និង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អាស្រ័យទៅតាមស្ថានបទល្មើសដែលអ្នកប្រើប្រាស់គេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមបានប្រព្រឹត្ត។

**ខ.ក្រមសីលធម៌នៃអ្នកសិល្បៈ**

ដើម្បីទប់ស្កាត់បាននូវរាល់សកម្មភាព ដែលបណ្តាលឱ្យមានព្យសនកម្មចំពោះវប្បធម៌ជាតិ និងដើម្បីសម្រេចបាននូវការលើកកម្ពស់ ការថែរក្សា ការពារសិល្បៈ ទំនៀមទម្លាប់ ប្រពៃណី និងអត្តសញ្ញាណជាតិឱ្យបានគង់វង្ស ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានដាក់ចេញប្រកាសស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦។ យោងតាមប្រការ២ នៃប្រកាសនេះ គឺមានគោលដៅដើម្បី "លើកកម្ពស់ឥរិយាបថ អត្តចរិត ផោហារស័ព្ទ សំណេរ និងប្រឌិតញាណរបស់សិល្បៈស្របតាមវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីដ៏ល្អផូរផង់របស់ជាតិ, លើកកម្ពស់សីលធម៌ គុណធម៌ សច្ចធម៌ និងសេចក្តីថ្លៃថ្នូរនៃអ្នកប្រកបមុខរបរពាក់ព័ន្ធនឹងវិស័យសិល្បៈ វប្បធម៌ ដើម្បីឧត្តមភាពបុគ្គល សង្គម និងដើម្បីជាគំរូដ៏ល្អប្រសើរសម្រាប់អ្នកបន្តវេន, លើកកម្ពស់ការប្រើប្រាស់សក្តានុពលវប្បធម៌ដើម្បីការអប់រំនិងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម"។

ប្រកាសនេះ បានកំណត់អំពីៈ កាតព្វកិច្ចទូទៅនៃអ្នកសិល្បៈ(ខ.១), កាតព្វកិច្ចនៃអ្នកបង្កើតស្នាដៃ(ខ.២), និងកាតព្វកិច្ចនៃអ្នកសម្តែង(ខ.៣)។

**ខ.១.កាតព្វកិច្ចទូទៅនៃអ្នកសិល្បៈ**

យោងតាមប្រការ៤ នៃប្រកាសនេះ សិល្បករត្រូវមានកាតព្វកិច្ចមួយចំនួន មានដូចខាងក្រោមៈ

- ត្រូវមានភក្តីភាពចំពោះជាតិ សាសនា និងព្រះមហាក្សត្រ
- ត្រូវប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាព ឯកភាពជាតិខ្ពស់ រស់នៅក្នុងភាពជាបងប្អូន ដោយចេះជួយគ្នាទៅវិញទៅមកស្របតាមវប្បធម៌ ប្រពៃណីដ៏ថ្លៃថ្លានៃដូនតាយើង
- ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌ គុណធម៌ សច្ចធម៌ ទាំងសំណេរ ទាំងការប្រើប្រាស់ពាក្យពេចន៍ កាយវិការ សកម្មភាព ឥរិយាបថ ការស្លៀកពាក់ ដោយរក្សាឱ្យបាននូវភាពថ្លៃថ្នូរ ដើម្បីរួមចំណែកលើកកម្ពស់សីលធម៌សង្គមនិងកិត្យានុភាពជាតិ
- ត្រូវគោរពស្រឡាញ់ការងារ ចំណេះ ជំនាញ ទាំងតម្លៃពិតខាងស្មារតីនិងបច្ចេកទេស, ត្រូវផ្ទេរចំណេះ ជំនាញដែលខ្លួនមានឱ្យបានដល់អ្នកបន្តវេនជំនាន់ក្រោយ

- ត្រូវមានមនសិការចូលរួមអនុវត្តឱ្យបានសម្រេចនូវ «គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌» និងលើកស្ទួយកិច្ចការសង្គម
- ត្រូវប្រកាន់ខ្ជាប់នូវមនសិការជាអ្នកបន្តវេនមរតកវប្បធម៌ដ៏ល្អផូរផង់របស់បុព្វបុរសយើង និងជាគំរូដ៏ប្រពៃថ្លៃថ្លាដល់អ្នកបន្តវេនជំនាន់ក្រោយៗទៀត
- ត្រូវចៀសវាងឱ្យបានដាច់ខាតនូវគ្រប់សកម្មភាពនិងឥរិយាបថទាំងឡាយ ដែលមានផលប៉ះពាល់ជាលក្ខណៈអវិជ្ជមានដល់វប្បធម៌ ប្រពៃណី និងកិត្យានុភាពជាតិ
- ត្រូវចៀសវាងឱ្យបាននូវប្រឌិតញាណ ការសម្តែងដែលមានលក្ខណៈអុជអាល បំបែកបំបាក់ ប្រកាន់ពូជសាសន៍ ព័ណ៌សម្បុរ និងជំនឿសាសនា។

### ខ.២.កាតព្វកិច្ចនៃអ្នកបង្កើតស្នាដៃ

ប្រការ៥ នៃប្រកាសដដែល បានចែងអំពីកាតព្វកិច្ចរបស់អ្នកបង្កើតស្នាដៃ មានដូចខាងក្រោម៖

- ត្រូវបង្កើតស្នាដៃចេញពីសមត្ថភាពនៃប្រឌិតញាណរបស់ខ្លួនដោយផ្ទាល់
- ត្រូវរក្សាឱ្យបាននូវព័ណ៌សម្បុរនិងអត្តសញ្ញាណជាតិ
- ត្រូវប្រមូលផ្តុំលើការអប់រំស្របតាម «គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌» និងត្រូវគោរពឱ្យបាននូវគោលការណ៍សច្ចធម៌ គុណធម៌ និងសោភណ្ឌភាពស្របតាមអត្តសញ្ញាណជាតិ
- ត្រូវបង្កប់នូវគំនិតនិងទស្សនៈល្អៗដែលមានគុណប្រយោជន៍ដល់ការលើកកម្ពស់ការអប់រំសីលធម៌ គុណធម៌ មនសិការស្នេហាជាតិ ស្នេហាវប្បធម៌ និងការអភិវឌ្ឍសង្គម
- ត្រូវប្រកាន់ខ្ជាប់នូវមនសិការចូលរួម គាំទ្រគ្រប់សកម្មភាពអប់រំនិងកិច្ចការសង្គម
- ត្រូវជៀសវាងឱ្យបាននូវការបង្កើតស្នាដៃដែលមានលក្ខណៈអុជអាល បំបែកបំបាក់ ប្រកាន់ពូជសាសន៍ ព័ណ៌-សម្បុរ និងជំនឿសាសនា
- ត្រូវតម្កល់ស្នាដៃរបស់ខ្លួនទុកជាកេរដំណែលសម្រាប់មនុស្សជំនាន់ក្រោយ ពិសេសចងក្រងឯកសារដែលបានសិក្សាស្រាវជ្រាវរកឃើញទុកជាក្បួនតម្រា។

### ខ.៣.កាតព្វកិច្ចនៃអ្នកសម្តែង

យោងតាមប្រការ៦ នៃប្រកាសដដែល អ្នកសម្តែងត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

- ត្រូវរក្សាឱ្យបាននូវសុជីវធម៌ សីលធម៌ ភាពថ្លៃថ្នូរ ទាំងកាយវិការ ការស្លៀកពាក់ និងវោហារសព្ទ
- ត្រូវគោរពវិន័យឱ្យបានត្រឹមត្រូវទាំងក្នុងពេលហាត់សម មុនសម្តែង ពេលកំពុងសម្តែង និងក្រោយពេលសម្តែង

- ត្រូវចៀសវាងឱ្យបាននូវអំពើទាំងឡាយណាដែលធ្វើឱ្យអាប់ឱនដល់វិជ្ជាជីវៈនៃអ្នកសិល្បៈ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ
- ត្រូវចៀសវាងឱ្យបានដាច់ខាតនូវការប្រើប្រាស់កាយវិការនិងពាក្យពេចន៍ដែលមានលក្ខណៈអាសអាភាស អសុរោះ ញុះញង់ អុជអាល និងបំបែកបំបាក់
- មិនត្រូវយកអារម្មណ៍មិនល្អពីខាងក្រៅទៅប្រើប្រាស់ក្នុងពេលសម្តែង ដែលនាំឱ្យប៉ះពាល់ ឬខូចខាតដល់គុណភាពសម្តែង ដល់កិត្តិយសសហការីរួមការងារជាមួយគ្នា និងត្រូវផ្ចង់អារម្មណ៍ដើម្បីលើកតម្លៃទាំងបច្ចេកទេស និងស្មារតីក្នុងការសម្តែង
- មិនត្រូវធ្វើឱ្យបាត់បង់គុណតម្លៃក្នុងពេលបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមល័ក្ខខ័ណ្ឌនៃកិច្ចសន្យាណាមួយឡើយ
- មិនត្រូវយកភាពល្បីល្បាញរបស់ខ្លួនទៅគាបសង្កត់ធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ទោះក្នុងរូបភាពណាក៏ដោយ។

**ករណីជាក់ស្តែងមួយ៖** កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ក្រុមប្រឹក្សាពិន័យនិងលើកសរសើររបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានកោះហៅអ្នកចម្រៀង និងអ្នកនិពន្ធបទ «កណ្តៀវអូនស្រួយ» និងបទ «ស្រណោះអង្រែ» ដែលបានផ្សព្វផ្សាយនៅលើបណ្តាញទំនាក់ទំនងសង្គម Facebook ដើម្បីណែនាំអប់រំ ដោយសារតែអត្ថន័យនៃចម្រៀងនេះ មានខ្លឹមសារប៉ះពាល់យ៉ាងខ្លាំងដល់វប្បធម៌ខ្មែរ។ ម្ចាស់និពន្ធបទចម្រៀងរូបនេះ បានទទួលស្គាល់កំហុស និងបានធ្វើកិច្ចសន្យាថានឹងមិននិពន្ធបទចម្រៀងដែលប៉ះពាល់ដល់វប្បធម៌សង្គមជាតិតទៅទៀតទេ។



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យា

ខ្ញុំបាទឈ្មោះ [redacted] កើតថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៨១ ជាអ្នកនិពន្ធបទចម្រៀងដែលមានចំណងជើងថា (កណ្ដៀវអូនស្រួយ) និងបទ (ស្រណោះអង្រែ) ជាបទចម្រៀងដែលប្រើពាក្យពេចន៍អសុរស ធ្វើឲ្យប៉ះពាល់ដល់សីលធម៌សង្គម ដែលធ្វើឲ្យមហាជនមានការមិនពេញចិត្ត និងបណ្ដាលឱ្យប៉ះពាល់ដល់តម្លៃសីលធមសង្គម។ ខ្ញុំបាទ [redacted] សូមធ្វើការសុំទោសជាសាធារណៈដល់មហាជន នឹងសូមសន្យាថាមិនតែងនិពន្ធបទចម្រៀងដែលបង្កឱ្យមានការប៉ះពាល់ដល់វប្បធម៌សង្គមជាតិតទៅទៀតទេ។

ខ្ញុំនឹងធ្វើការចុះបញ្ជីផលិតកម្មឱ្យបានត្រឹមត្រូវតាមច្បាប់ នឹងយកទេពកោសល្យដែលខ្ញុំមាន មកប្រើប្រាស់ក្នុងផ្លូវវិជ្ជមានដើម្បីជួយលើកស្ទួយតម្លៃសិល្បៈវប្បធម៌ជាតិ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២

ស្នាមមេដៃសាមីខ្លួន

[redacted]

ប្រភព៖ https://dap-news.com/entertianment/2020/06/10/60479/

រូបភាពទី ២.៣៖ អ្នកនិពន្ធបទចម្រៀងធ្វើកិច្ចសន្យាទទួលស្គាល់កំហុសលើការនិពន្ធរបស់ខ្លួន

### ២.២.៦.ការហាមឃាត់ការផ្សព្វផ្សាយជីវិតឯកជនរបស់បុគ្គល

ធម្មជាតិ បង្កើតចក្រវាលធំល្វឹងល្វើយ គ្មានដែនកំណត់ ដោយមានវត្ថុមានពាន់លានភពច្រើនអនេក។ មនុស្សកើតនិងរស់រានមានជីវិតលើភពផែនដី ទោះបីធម្មជាតិបានបង្កើតរូបកាយ ភេទ ពណ៌សម្បុរ ស ខ្មៅ លឿង ស្រអែម ពូជសាសន៍ផ្សេងៗមនុស្សខុសពីសត្វ ត្រង់មនុស្សកើតចេញពីផ្ទៃមាតា ទទួលបាននូវសិទ្ធិ។ យោងតាមទ្រឹស្ដីច្បាប់ សិទ្ធិរបស់មនុស្ស ដែលហៅថា រូបវន្តបុគ្គល មានសិទ្ធិផ្នែកសេដ្ឋកិច្ច ដែលជាសិទ្ធិបេតិកភណ្ឌ និងសិទ្ធិក្រៅបេតិកភណ្ឌ។ សិទ្ធិក្រៅបេតិកភណ្ឌនេះ មានបូរណភាពផ្លូវចិត្តផងដែរ។ តើបូរណភាពផ្លូវចិត្តនេះ មានអ្វីខ្លះដែរ?

ជាការពិតណាស់ ជីវិតឯកជន ជាផ្នែកមួយនៃបូរណភាពផ្លូវចិត្ត។ ជីវិតឯកជនមានដូចជា ជីវិតទាំងឡាយណាដែលបុគ្គលម្នាក់ៗស្ថិតក្នុងជីវិតរក្សាភាពសម្ងាត់ផ្ទាល់ខ្លួន ដែលច្បាប់ទទួលស្គាល់ដែលបុគ្គលយើងគ្រប់រូបមានសិទ្ធិការពារ។ វាមានដូចជា ទំនាក់ទំនងក្រុមគ្រួសារ ញាតិមិត្ត សេចក្ដីឆ្លើយឆ្លងរបស់បុគ្គលលិខិតជា

សំណេរ តាមទូរស័ព្ទ តាមឆាត(Chat)គ្រប់ប្រភេទលើបណ្តាញសង្គម) លំនៅ ទីសម្រាកកម្សាន្តពេលវិស្សមកាល សេចក្តីស្នេហា ការបែកបាក់គ្រួសារ ការលែងលះ សុខភាព វត្ថុអនុស្សាវរីយ៍ផ្ទាល់ខ្លួន ជីវិតផ្លូវភេទ រហូតដល់ទ្រព្យសម្បត្តិរបស់បុគ្គលផ្ទាល់ខ្លួនដែលមិនបានកើតចេញពីទង្វើខុសច្បាប់។

នៅក្នុងបរិបទនៃការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតនេះ រាល់អ្នកធ្វើការផ្សព្វផ្សាយ ត្រូវតែគោរពនូវជីវិតឯកជនរបស់បុគ្គល។ បើយើងតាមដាន និងសង្កេតព័ត៌មានដែលបានផ្សព្វផ្សាយកន្លងមក និងនៅពេលបច្ចុប្បន្ននេះ ការផ្សព្វផ្សាយមួយចំនួន នៅតែបំពានសិទ្ធិនៃជីវិតឯកជនរបស់បុគ្គល។ ដូចជា ការជេរប្រមាថតាមការផ្សព្វផ្សាយតាមរូបភាពផ្សេងៗ តាមបណ្តាញសង្គម Facebook, Youtube,... អ្នកលេងបណ្តាញសង្គម មានការប្រើប្រាស់ពាក្យសម្តីជេរប្រមាថ ដល់បុគ្គលដទៃ យ៉ាងអាណាធិបតេយ្យ មិនខ្លាចញញើតច្បាប់ បាត់បង់សេចក្តីថ្លៃថ្នូររបស់មនុស្ស រហូតដល់ប៉ះពាល់ដល់វប្បធម៌ កិត្តិភាពជាតិ។

ម៉្យាងវិញទៀត ការយកព័ត៌មានជាសំណេររូបភាព ខ្សែអាត់វីដេអូ សំឡេង រូបភាព យកទៅផ្សព្វផ្សាយ ឬចែកផ្សាយ ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីសាមីបុគ្គលនៃម្ចាស់សិទ្ធិទេ អ្នកធ្វើការផ្សព្វផ្សាយក៏ពុំមានសិទ្ធិផ្សព្វផ្សាយដែរ លើកលែងតែ មានការព្រមព្រៀងដោយតុណ្ហីភាព( ការព្រមព្រៀងដោយស្ងៀមស្ងាត់ ដោយវាយតម្លៃជាលក្ខណៈសត្យានុម័ត) ទើបអ្នកផ្សព្វផ្សាយ អាចយកទៅផ្សព្វផ្សាយបាន ក្នុងសភាពឥរិយាបទរបស់អ្នកសម្តែងល្អ ឬសមរម្យទទួលយកបានសម្រាប់ការផ្សព្វផ្សាយ។ ដូចជា ការថ្លែងសុន្ទរកថា នៅទីសាធារណៈក្នុងពិធីណាមួយរបស់ថ្នាក់ដឹកនាំ ក្រសួង-ស្ថាប័ន ឬអ្នកតំណាងប្រទេសជាតិទាំងមូលជាដើម។ ប៉ុន្តែ ប្រសិនបើការថត ផ្តិតយករូបភាព ឬទាញយកសំឡេងរបស់អ្នកសម្តែង ក្នុងសភាពឥរិយាបទមិនទំនង ដូចជា ពេលនិយាយសម្តែង បុគ្គលបានបង្ហាញកិរិយាមួយចំនួនដូចជា ស្វាប ចំហមាត់ លើកដៃ ជើង ប្រេងេងប្រេងាង ខុសទំនង មិនធម្មតានោះ អ្នកផ្តិតយករូបភាពទៅផ្សព្វផ្សាយ មិនអាចយកទៅផ្សព្វផ្សាយបានឡើយ ។

ជីវិតឯកជន ត្រូវបានច្បាប់ការពារ។ គ្មានបុគ្គលណាម្នាក់ចង់ដឹង សម្លឹងមើល យកត្រចៀកស្តាប់ ឬ រពឹសដៃ ជើង ឆ្គឹះ ឆ្កៀល ស៊កសៀត កកូរកកាយ បរិយាយ បានឡើយ។

### ២.២.៧.សិទ្ធិផ្សព្វផ្សាយតាមសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត

ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត បាននិងកំពុងគំរាមកំហែងពិភពលោកយ៉ាងធ្ងន់ធ្ងរនាពេលបច្ចុប្បន្ន ជាពិសេសក្នុងបណ្តាប្រទេសអភិវឌ្ឍន៍។ យោងតាមរបាយការណ៍រួមរបស់មជ្ឈមណ្ឌលសិក្សាយុទ្ធសាស្ត្រនិងអន្តរជាតិ(CSIS)[២៨] និងក្រុមហ៊ុនម៉ាកខាហ្វី(McAfee)[២៩] ដែលបានចុះផ្សាយកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ បានឱ្យដឹងថា ពិភពលោកបានខាតបង់ថវិកាប្រមាណជា៦០០ កោដិដុល្លារក្នុងមួយឆ្នាំ ដោយសារតែបទឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត។[៣០] ការរីករាលដាលនៃឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ធ្វើឱ្យអង្គការអន្តរជាតិធំៗមួយចំនួន ដូចជា អង្គការសហប្រជាជាតិ សហភាពអឺរ៉ុបជាដើម បានបង្ហាញនូវក្តីបារម្ភជាខ្លាំង និងបានដាក់ចេញនូវបទដ្ឋានគតិយុត្តនានាដើម្បីទប់ស្កាត់។

បើក្រឡេកមកមើលប្រទេសកម្ពុជាឯនេះវិញ ដោយសារតែប្រព័ន្ធអ៊ីនធឺណិតមានការរីកចម្រើន និងចំនួននៃអ្នកប្រើប្រាស់មានការកើនឡើងខ្លាំង នោះមធ្យោបាយនៃការប្រព្រឹត្តបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាក៏កាន់តែងាយស្រួល និងអាចកើតឡើងបានគ្រប់ពេលវេលាផងដែរ។ ដោយមើលឃើញពីបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតមួយឡើង។ សេចក្តីព្រាងច្បាប់នេះ គឺមានគោលបំណង ដើម្បីប្រយុទ្ធប្រឆាំងរាល់បទល្មើសនានា ដែលប្រព្រឹត្តឡើងតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ព្រមទាំងធានាសុវត្ថិភាព និងការពារផលប្រយោជន៍ស្របច្បាប់នៃការប្រើប្រាស់ និងការអភិវឌ្ឍបច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មាន(សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត, មាត្រា១ និងមាត្រា២)។

បទល្មើសដែលអាចចាត់ចូលជាបទឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានច្រើនប្រភេទដូចជា ការតភ្ជាប់ដោយខុសច្បាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រអ្នកដទៃ ចារកម្មទិន្នន័យ ការជ្រៀតជ្រែកទិន្នន័យ ការជ្រៀតជ្រែកប្រព័ន្ធ ការចែកចាយរូបអាសអាភាសកុមារ ការបំពានកម្មសិទ្ធិបញ្ញា ការឆបោកតាមរយៈកុំព្យូទ័រ ព្រមទាំងបទល្មើសផ្សេងទៀតដែលប៉ះពាល់ដល់សន្តិសុខជាតិ ប្រពៃណីល្អរបស់សង្គមជាតិ និងបុគ្គលជាដើម។

ចំពោះបទល្មើស ដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយ នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត គឺមានចំនួន៣មាត្រា។ មាត្រា២៧ នៃសេចក្តីព្រាងច្បាប់នេះ បានចែងអំពីបទល្មើសនៃការចែកចាយរូបអាសអាភាសកុមារ ដែលមានសេចក្តីថា៖

១. ជនណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

---

[២៨] The Center for Strategic and International Studies។

[២៩] ជាឈ្មោះក្រុមហ៊ុនលក់កម្មវិធីកំចាត់មេរោគកុំព្យូទ័រ។

[៣០]James Lewis, *Economic Impact of Cybercrime No Slowing Donw* (២០១៨), ទំព័រទី៦, ការយោងឯកសារនេះ តាមការស្រាវជ្រាវនៅ https://www.csis.org/analysis/economic-impact-cybercrime (បានពិគ្រោះនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០)។

ក. ផលិតរូបអាសអាភាសកុមារសម្រាប់យកទៅចែកចាយតាមរយៈប្រព័ន្ធកុំព្យូទ័រ

ខ. ផ្តល់ឬដាក់ឱ្យមានរូបអាសអាភាសកុមារតាមរយៈប្រព័ន្ធកុំព្យូទ័រ

គ. ចែកចាយឬបញ្ជូនរូបអាសអាភាសកុមារតាមរយៈប្រព័ន្ធកុំព្យូទ័រ

ឃ. ទាញយកឬផ្តល់ឱ្យអ្នកដទៃនូវរូបអាសអាភាសកុមារតាមប្រព័ន្ធកុំព្យូទ័រ

ង. ធ្វើជាម្ចាស់រូបអាសអាភាសកុមារនៅក្នុងប្រព័ន្ធកុំព្យូទ័រឬឧបករណ៍ស្តុកទិន្នន័យ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលទៅ ១០ ០០០ ០០០(ដប់លាន)រៀល។

២. រូបអាសអាភាសកុមារដែលមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើ រួមមានរូបអាសគ្រាមដែលអាចមើលឃើញនឹងភ្នែកបាន៖

ក. អនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តអារម្មណ៍ផ្លូវភេទ

ខ. បុគ្គលម្នាក់ដែលបញ្ចេញកាយវិការដូចនិងអនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តអារម្មណ៍ផ្លូវភេទ

គ. រូបភាពជាក់ស្តែងដែលតំណាងឱ្យអនីតិជនដែលសំដែងចេញនូវការប្រព្រឹត្តអារម្មណ៍ផ្លូវភេទ។

បន្ថែមពីលើនេះ មាត្រា២៨ ហាមមិនឱ្យជនគ្រប់រូប តាក់តែងមាតិកាព័ត៌មាន ផ្សព្វផ្សាយ ចែកចាយបន្តនូវខ្លឹមសារណាមួយ ដែលជាព័ត៌មានក្លែងក្លាយ ព័ត៌មានដែលប៉ះពាល់ដល់ឯករាជ្យជាតិ បូរណភាពទឹកដី សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ស្ថិរភាពនយោបាយ ព័ត៌មានមិនពិតដែលអាប់ឱនដល់ស្ថាប័នជាតិ ប្រពៃណីល្អរបស់ជាតិ ឬការតាក់តែងខ្លឹមសារគំរាមកំហែងបុគ្គលជាដើម។[៣១] ម្យ៉ាងវិញទៀត សេចក្តីព្រាងច្បាប់ដដែល បានចែងអំពីបទល្មើសកម្មសិទ្ធិបញ្ញា ប៉ុន្តែចំពោះការអនុវត្ត គឺយោងតាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។[៣២]

### ២.២.៨.ការគ្រប់គ្រង ការប្រឆាំង និងការទប់ស្កាត់លើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

យោងតាមប្រកាសអន្តរក្រសួងលេខ ១៧០ ប្រក.អន្តរក្រ. ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានធ្វើឡើងដោយក្រសួងពាក់ព័ន្ធសំខាន់ៗចំនួនបី គឺក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីគ្រប់គ្រង ប្រឆាំង និងទប់ស្កាត់រាល់ការផ្សព្វផ្សាយ ឬការចែកចាយខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត ដែលដំណើរ

[៣១]មាត្រា២៨ នៃសេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត។ សេចក្តីព្រាងច្បាប់នេះ ពុំបានបញ្ជាក់កាលបរិច្ឆេទឡើយ។ ការយោងឯកសារនេះ តាមការស្រាវជ្រាវនៅ https://data.opendevelopmentmekong.net/dataset/draft-cybercrime-law/ resource/ ef0154d3-7998-494f-9817-dca2d14d2d03?inner_span=True (បានពិគ្រោះនៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២០)។

[៣២] មាត្រា២៩ នៃសេចក្តីព្រាងច្បាប់ដដែល។

ការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានចេតនាបង្កជាចលាចលបណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ។[៣៣]

ក្រសួងនីមួយៗ បានចាត់តាំងអង្គភាពជំនាញរបស់ខ្លួន ដើម្បីធ្វើការសហការគ្នា តាមដាន សិក្សាស្រាវជ្រាវ ស្វែងរក ការធ្វើអាជីវកម្មនិងការផ្សព្វផ្សាយល្មើសច្បាប់តាមគេហទំព័រ និងរាល់បណ្តាញទំនាក់ទំនងសង្គម ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។ ក្នុងនោះដែរ ក្រសួងព័ត៌មាន ប្រតិបត្តិការដោយអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ ក្រសួងមហាផ្ទៃប្រតិបត្តិការដោយអគ្គស្នងការនគរបាលជាតិ និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ប្រតិបត្តិការដោយនិយ័តករទូរគមនាគមន៍កម្ពុជា។[៣៤]

**ក.ភារកិច្ចរបស់ក្រសួងព័ត៌មានលើការផ្សព្វផ្សាយខុសច្បាប់**

យោងតាមប្រការ៦ នៃប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងព័ត៌មានត្រូវមានតួនាទីមួយចំនួនដូចខាងក្រោម៖

- គ្រប់គ្រងព័ត៌មានដែលផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិកជាអាទិ៍: រាល់ខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀតតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ចាត់វិធានការលើប្រព័ន្ធផ្សព្វផ្សាយតាមអេឡិចត្រូនិក ដែលមានច្បាប់អនុញ្ញាតធ្វើអាជីវកម្មពីក្រសួងព័ត៌មាន ដែលធ្វើការផ្សព្វផ្សាយល្មើសច្បាប់។
- ផ្តល់ព័ត៌មានជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចាត់វិធានការបិទគេហទំព័រ និង/ឬ Page បណ្តាញទំនាក់ទំនងសង្គម ដែលបើកអាជីវកម្មផ្សព្វផ្សាយដោយខុសច្បាប់ និង/ឬ ការផ្សព្វផ្សាយព័ត៌មានដោយចេតនាដើម្បីបង្កចលាចលក្នុងសង្គម ធ្វើឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ច សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ។
- សហការជាមួយក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធ ចាត់វិធានការបង្ក្រាបការធ្វើអាជីវកម្មតាមប្រព័ន្ធអ៊ីនធឺណិតដែលល្មើសច្បាប់។
- ផ្តល់ព័ត៌មានជូនក្រសួងមហាផ្ទៃនូវអាសយដ្ឋាន គេហទំព័រ និងគណនីបណ្តាញទំនាក់ទំនងសង្គមទាំងឡាយដែលធ្វើការផ្សព្វផ្សាយល្មើសច្បាប់ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។

---

[៣៣] ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺ ណិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា, លេខ ១៧០ ប្រក/អន្តរក្រ, ២៨ ឧសភា ២០១៨, ប្រការ១-២។

[៣៤] ប្រកាសអន្តរក្រសួងដដែល, ប្រការ៤។

**ខ.ភារកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

យោងតាមប្រការ៧ នៃប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវមានចំណាត់ការមួយចំនួនដូចខាងក្រោម៖

- ចាត់វិធានការយ៉ាងតឹងរឹងចំពោះក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងអស់ ដែលកំពុងដំណើរការធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាគ្មានច្បាប់អនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- តម្រូវឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិតទាំងអស់ ដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានកម្មវិធីសុហ្វវែរ និងបំពាក់ឧបករណ៍គ្រប់គ្រងអ៊ីនធឺណិត ដើម្បីងាយស្រួលក្នុងការច្រោះ ឬធ្វើការរាំងខ្ទប់ចំពោះគេហទំព័រ គណនី ឬទំព័ររបស់បណ្តាញទំនាក់ទំនងសង្គម ដែលធ្វើអាជីវកម្ម និង/ឬ ធ្វើការផ្សព្វផ្សាយល្មើសច្បាប់។
- សហការជាមួយក្រសួងព័ត៌មាន ឬ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង/ឬ ស្នើសុំកិច្ចសហការពីក្រសួង-ស្ថាប័នអន្តរ-ជាតិពាក់ព័ន្ធដទៃទៀត រាំងខ្ទប់ ឬបិទគេហទំព័រ និង/ឬ ទំព័របណ្តាញទំនាក់ទំនងសង្គម ដែលធ្វើអាជីវកម្មខុសច្បាប់ និង/ឬ ធ្វើការផ្សព្វផ្សាយល្មើសច្បាប់ ដែលមានលក្ខណៈញុះញង់ បំបែកបំបាក់សាមគ្គីភាព ការរើសអើងចេតនាបង្កចលាចល ដែលអាចបណ្តាលឱ្យអន្តរាយដល់សន្តិសុខជាតិ ផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម។
- សហការផ្តល់ព័ត៌មានជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។

**គ.ភារកិច្ចរបស់ក្រសួងមហាផ្ទៃ**

យោងតាមប្រការ៨ នៃប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃត្រូវមានវិធានការដូចខាងក្រោម៖

- ធ្វើការសិក្សា ស្រាវជ្រាវ ស្វែងរកប្រភពគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលធ្វើការផ្សព្វផ្សាយល្មើសច្បាប់ បង្កចលាចលក្នុងសង្គមអាចបណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ ប្រពៃណីជាតិ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។
- សហការផ្តល់ព័ត៌មានជូនក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការចំពោះការធ្វើអាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលគ្មានច្បាប់អនុញ្ញាត។

- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាត់វិធានការបង្ក្រាបបទល្មើសធ្វើអាជីវកម្មតាមបណ្តាញទំនាក់ទំនងសង្គម ដែលប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធឺណិត និង/ឬ ធ្វើការផ្សព្វផ្សាយព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀត ដែលល្មើសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ២.៣.បទល្មើសនិងទោសចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

ការបង្កើតច្បាប់ឡើង គឺដើម្បីមានភាពងាយស្រួលក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេស ឱ្យមានសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អ ព្រោះច្បាប់មានអនុភាពចាប់បង្ខំឱ្យអនុវត្តនិងធ្វើតាម។ រាល់ការផ្សព្វផ្សាយទាំងឡាយនៅតាមប្រព័ន្ធអ៊ីនធឺណិត ប្រសិនបើ បុគ្គលមិនអនុវត្ត ឬធ្វើតាមច្បាប់ដែលបានដាក់ចេញអាចនឹងត្រូវទទួលទោសទណ្ឌ។

### ២.៣.១.វិសាលភាពនៃការផ្សព្វផ្សាយតាមវិធានពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

បទល្មើស និងទោសចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត មានកំណត់នៅក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ២០១៩ ដូចខាងក្រោម៖

- មាត្រា៥៣ អំពើល្មើសលើការលួចប្រើប្រាស់អត្តសញ្ញាណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃមាត្រា២២។
- មាត្រា៥៤ អំពើល្មើសលើការមិនរាយការណ៍អំពីព័ត៌មានឬហេតុការណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន)រៀល ទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះអន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រា២៥។
- មាត្រា៥៥ អំពើផ្តល់ព័ត៌មានមិនពិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំនិងត្រូវពិន័យជាលុយពី១០០ ០០០(មួយសែន)រៀល ទៅ២ ០០០ ០០០(ពីរលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា២៥។
- មាត្រា៥៦ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ត្រូវបញ្ឈប់សកម្មភាពឬប្រតិបត្តិការអាជីវកម្មនិងត្រូវទទួលការផាកពិន័យជាប្រាក់មិនលើសពី១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា២៦។ ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល។
- មាត្រា៥៧ អំពើល្មើសលើការមិនអនុវត្តតាមបទប្បញ្ញត្តិស្តីពីព័ត៌មានអប្បបរមាក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹង

បញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា២៩។ ក្នុងករណីមិនរាងចាល ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាបុគ្គលផ្តល់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

- មាត្រា៥៨ អំពើល្មើសលើការផ្ញើទំនាក់ទំនងពាណិជ្ជកម្មដែលមិនបានស្នើសុំ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣០។ ក្នុងករណីមិនរាងចាល ត្រូវព្យួរឬដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតជាអន្តរការីឬបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬបិទមិនឱ្យដំណើរការនូវប្រព័ន្ធផ្សព្វផ្សាយឬមធ្យោបាយអេឡិចត្រូនិករបស់អ្នកផ្ញើ។
- មាត្រា៥៩ អំពើល្មើសលើការក្លែងប្រព័ន្ធអេឡិចត្រូនិកនិងកូដព្យាបាទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃមាត្រា៣១។
- មាត្រា៦០ អំពើល្មើសលើការមិនអនុវត្តកាតព្វកិច្ចការពារទិន្នន័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ២(ពីរ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលដែលរក្សាព័ត៌មានជាលក្ខណៈឯកជនក្រោមទម្រង់អេឡិចត្រូនិក ដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៣២។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ២(ពីរ)ឆ្នាំនិងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី២នៃមាត្រា៣២។
- មាត្រា៦៣ អំពើល្មើសលើការធ្វើប្រតិបត្តិការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀល ទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១នៃមាត្រា៤៦។
- មាត្រា៦៤ អំពើល្មើសលើការក្លែងបន្លំឧបករណ៍ទូទាត់សងប្រាក់ជាអេឡិចត្រូនិក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀល ទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ចំពោះបុគ្គលទាំងឡាយដែលប្រព្រឹត្តអំពើផ្ទុយនឹងបទបញ្ញត្តិនៃកថាខណ្ឌទី៥នៃមាត្រា៤៧។

### ២.៣.២.ដែនអនុវត្តនៃការផ្សព្វផ្សាយតាមវិធានរបបសារព័ត៌មាន

បទល្មើស និងទោសចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត មានចែងនៅក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ ដូចខាងក្រោម៖

- ការប្រព្រឹត្តបទល្មើសដែលមានចែងដូចមាត្រា១១ ខាងលើនេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅ ប្រាំលានរៀល (៥ ០០០ ០០០ រៀល)។
- ជនណាដែលប្រព្រឹត្តល្មើសដូចមាត្រា១២ ខាងលើនេះ គឺ និយោជក និពន្ធនាយក ឬអ្នកនិពន្ធអត្ថបទ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលានរៀល (៥ ០០០ ០០០ រៀល) ទៅដប់ប្រាំលានរៀល (១៥ ០០០ ០០០ រៀល) ដោយមិនទាន់គិតដល់ការផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។
- ការប្រព្រឹត្តបទល្មើសដូចមាត្រា១៣ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ពីរលានរៀល (២ ០០០ ០០០ រៀល)ទៅ ដប់លានរៀល (១០ ០០០ ០០០ រៀល)។
- អំពើបំពានដូចមានចែងនៅមាត្រា១៤ អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅ ប្រាំលានរៀល (៥ ០០០ ០០០ រៀល)។
- មាត្រា១៦ ការផ្សាយពាណិជ្ជកម្មភូតកុហក អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលានរៀល (១ ០០០ ០០០ រៀល) ទៅ ប្រាំលានរៀល (៥ ០០០ ០០០ រៀល)។

### ២.៣.៣.វិសាលភាពនៃការផ្សព្វផ្សាយក្នុងវិស័យសុខាភិបាល

បទល្មើស និងទោសនៅក្នុងវិស័យសុខាភិបាលពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត មានដូចខាងក្រោម៖

#### ក.ការផ្សព្វផ្សាយពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា

បទល្មើស ទោស និងទណ្ឌកម្មចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត តាមច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ឆ្នាំ២០០០ ត្រូវបានកំណត់ដូចខាងក្រោម៖

- មាត្រា៦៣ ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា២១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន)រៀល ដល់ ១០ ០០០ ០០០ (ដប់លាន)រៀល ឬទោសណាមួយនៃទោសទាំងពីរនេះ។
- មាត្រា៦៤ ក្នុងករណីមិនរាងចាលល្មើសនឹងមាត្រា២១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងការផ្តន្ទាទោសពិន័យជាប្រាក់ ទាំងការផ្តន្ទាទោសដាក់ពន្ធនាគារដោយពុំទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ ចំពោះបច្ច័យនៃបទល្មើសដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬដល់អាយុជីវិតរបស់អ្នកប្រើ។

- មាត្រា៦៥ ផលិតផលទំនិញ និងសម្ភារៈទាំងអស់ដែលជាកម្មវត្ថុនៃការបង្កឱ្យមានបទល្មើសនឹងមាត្រា២១ នៃច្បាប់នេះ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។ ការរឹបអូសជាសមត្ថកិច្ចរបស់តុលាការ។ ការខូចខាតផ្សេងទៀត ដែលបណ្ដាលមកពីបទល្មើសនឹងមាត្រា២១ នៃច្បាប់នេះ ជនល្មើសត្រូវទទួលខុសត្រូវខាងនីតិរដ្ឋប្បវេណី ទៀតផង។
- មាត្រា៧០ ភ្នាក់ងារ ឬមន្ត្រីមានសមត្ថកិច្ចដែលបានឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួន ក្នុងការអនុវត្តមាត្រា២១ នៃច្បាប់នេះ ត្រូវទទួលទោសទណ្ឌកម្មរដ្ឋបាលកំរិតធ្ងន់ ព្រមទាំងទោសទាំងឡាយដែលមានចែងក្នុងមាត្រា៦៣ នៃច្បាប់នេះ ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត។

**ខ.ការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ**

ទោសប្បញ្ញត្តិចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត មានកំណត់នៅក្នុងអនុក្រឹត្យស្ដីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ឆ្នាំ២០០៥ ដូចខាងក្រោម៖

- អំពើល្មើសដូចមានចែងក្នុងមាត្រា១៣ ខាងលើ តាមមាត្រា១៨ នៃអនុក្រឹត្យនេះ ការអនុវត្តទោសប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ត្រូវអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផល ទំនិញ និងសេវា ឬតាមច្បាប់ផ្សេងៗទៀតជាធរមាន។

**គ.ការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធឱសថ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវិជ្ជសាស្ត្រ**

បទល្មើស ទោស និងទណ្ឌកម្មចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតពាក់ព័ន្ធនឹងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបុរាណ គ្រឿងសំអាង ផលិតផលសម្រាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ មានដូចខាងក្រោម៖

- ប្រការ៤ ការប្រព្រឹត្តល្មើស ដូចមានចែងនៅប្រការ១, ២, និង៣ ត្រូវផ្ដន្ទាទោសតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា១៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជ-សាស្ត្រ និងជំនួយវេជ្ជសាស្ត្រ គឺត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ដល់ ៥ ០០០ ០០០(ប្រាំលាន)រៀល។ និងតាមច្បាប់ស្ដីពីការគ្រប់គ្រងឱសថ ត្រង់មាត្រា១០ថ្មី(ពិន័យជាប្រាក់ពី មួយលានរៀល ទៅ ប្រាំលានរៀល និងករណីធ្ងន់ធ្ងរ ត្រូវផ្អាកផលិតកម្ម អាហរណៈកម្ម និងពាណិជ្ជកម្មឱសថ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការដើម្បីផ្ដន្ទាទោសតាមច្បាប់), មាត្រា១១ថ្មី (ពិន័យជាប្រាក់ពី ពីរលានរៀលទៅដប់លានរៀល ឬផ្ដន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ៦ខែ ឬទោសទាំងពីរនេះ), មាត្រា១២ថ្មី(ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ និងពិន័យជាប្រាក់ពី

ម្ភៃលានរៀល ដល់ហាសិបលានរៀល)។ និងមាត្រា១៦ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ក្នុងករណីនៃការផ្សាយពាណិជ្ជកម្មភូតកុហក ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី មួយលានរៀល ដល់ប្រាំលានរៀល។

**ឃ.ការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់**

ទណ្ឌកម្មចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ត្រូវបានកំណត់នៅអនុក្រឹត្យស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ ឆ្នាំ២០១១ ដូចខាងក្រោម៖

- អំពើល្មើសដូចចែងក្នុងមាត្រា៥, ៦, ៧, ៨ នៃអនុក្រឹត្យនេះ ត្រូវបានកំណត់ទណ្ឌកម្មតាម មាត្រា១០ គឺក្រុមហ៊ុនថ្នាំជក់ ផលិតករក្នុងស្រុក អ្នកនាំចូលផលិតផលថ្នាំជក់ អាជីវករ អ្នកពាក់ព័ន្ធនឹងការផ្សព្វផ្សាយ និងអ្នកចែកចាយផលិតផលថ្នាំជក់ ដែលមិនគោរពបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្ម មានដូចជា ព្រមានជាលាយលក្ខណ៍អក្សរ, ដកហូតផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយផលិតផលថ្នាំជក់ផ្សេងៗទៀត, ផ្អាកការប្រកបអាជីវកម្មជាបណ្តោះអាសន្ន, ឬបិទអាជីវកម្មជាស្ថាពរ ក្នុងករណីមិនរាងចាល។

**២.៣.៤.វិសាលភាពនៃការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌកម្មសិទ្ធិបញ្ញានៃសិទ្ធិអ្នកនិពន្ធ**

បទល្មើស និងទោសចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត តាមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលឆ្នាំ២០០៣ មានដូចខាងក្រោម៖

- កថាខណ្ឌទី២ មាត្រា៦៤ បទល្មើសនៃការផលិតឬការផលិតឡើងវិញ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន)រៀល ទៅ ២៥ ០០០ ០០០(ម្ភៃប្រាំលាន)រៀល ឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១២(ដប់ពីរ)ខែ។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង។ កថាខណ្ឌទី៤ បទល្មើសនៃការសម្តែងឬការផ្សព្វផ្សាយ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន)រៀលទៅ៥ ០០០ ០០០(ប្រាំលាន)រៀលឬ/និងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៣(បី)ខែ។ ករណីបទល្មើសបានប្រព្រឹត្តច្រើនដង ការផ្តន្ទាសទោសត្រូវគុណនឹងចំនួននៃការប្រព្រឹត្ត។ ករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដងនៃទោសពីមុន។

**២.៣.៥.ដែនអនុវត្តនៃការផ្សព្វផ្សាយក្នុងក្របខ័ណ្ឌវប្បធម៌ជាតិ**

ទណ្ឌកម្មចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត មានកំណត់នៅក្នុងប្រកាសស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈ ឆ្នាំ២០១៦ ដូចខាងក្រោម៖

- ប្រការ៨ ពិន័យ អ្នកសិល្បៈទាំងក្នុងអាជីពនិងមហាជនដែលបាននិងកំពុងធ្វើសកម្មភាពទាក់ទងនឹងវិស័យសិល្បៈវប្បធម៌ ហើយបានប្រព្រឹត្តផ្ទុយនឹងក្រមសីលធម៌នៃអ្នកសិល្បៈនេះ និង/ឬ បណ្តាលឱ្យមានព្យសនកម្មដល់សិល្បៈ វប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីជាតិ នឹងត្រូវទទួលរងពិន័យទៅតាមស្ថាន

កំហុសឆ្គងដែលបានប្រព្រឹត្តមានជាអាទិ៍ ណែនាំ ឬស្តីបន្ទោសដោយផ្ទាល់មាត់ និង/ឬ ព្រមានជាលាយលក្ខណ៍អក្សរផ្សព្វផ្សាយជាសាធារណៈ, ផ្អាកមិនឱ្យធ្វើសកម្មភាពទាក់ទងនឹងវិស័យសិល្បៈវប្បធម៌ក្នុងរយៈពេលណាមួយស្របតាមកំហុសឆ្គងនៃអ្នកសិល្បៈនោះបានប្រព្រឹត្ត។

### ២.៣.៦.ក្របខ័ណ្ឌនៃជីវិតឯកជនរបស់បុគ្គល

បទល្មើស ទោស និងទណ្ឌកម្មចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត មានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ដូចខាងក្រោម៖

- មាត្រា ៧៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧(ការទាមទារសំណងនៃការខូចខាតផ្នែកសតិអារម្មណ៍ដោយសារការបរិហារកេរ្តិ៍)។ ក្នុងករណី បើបុគ្គល ត្រូវបានបុគ្គលដទៃទៀតផ្សព្វផ្សាយបរិហារតាមប្រព័ន្ធអ៊ីនធឺណិត ធ្វើឱ្យអាប់ឱនកេរ្តិ៍ឈ្មោះក្នុងសង្គម។
- មាត្រា ៣០២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩(បទប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល)។ ក្នុងករណីដែល បុគ្គលត្រូវបានគេថតរូបដោយគ្មានការអនុញ្ញាត នៅទីកន្លែងឯកជន ហើយយកទៅផ្សព្វផ្សាយជាសាធារណៈនៅតាមប្រព័ន្ធអ៊ីនធឺណិតដោយគ្មានការអនុញ្ញាត។ ក៏ប៉ុន្តែ អាចចាត់ទុកថាជាការព្រមព្រៀងដោយតុណ្ហីភាព បើសិនជា បុគ្គលដែលត្រូវបានគេថតរូបនោះ គាត់បានដឹងថា គេយករូបគាត់ទៅផ្សព្វផ្សាយជាសាធារណៈនៅលើប្រព័ន្ធអ៊ីនធឺណិតដែរ តែមិនជំទាស់។ ការយល់ព្រមឱ្យថតរូប ពុំមែនមានន័យថា ជាការយល់ព្រមឱ្យយករូបដែលថតនោះ ទៅផ្សព្វផ្សាយនៅលើប្រព័ន្ធអ៊ីនធឺណិតឡើយ។ បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ២ ០០០ ០០០(ពីរលាន)រៀល។
- មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩(បទបរិហារកេរ្តិ៍ជាសាធារណៈ)។ ក្នុងករណី បើបុគ្គលត្រូវបានបុគ្គលដទៃទៀត បរិហារកេរ្តិ៍ជាសាធារណៈនៅតាមប្រព័ន្ធអ៊ីនធឺណិត ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទ។ បទល្មើសនេះ ត្រូវពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល។
- មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩( បទជេរប្រមាថជាសាធារណៈ)។ ក្នុងករណី បើបុគ្គលត្រូវបានបុគ្គលដទៃទៀត ជេរប្រមាថ ផ្សព្វផ្សាយជាសារធាណៈនៅតាមប្រព័ន្ធអ៊ីនធឺណិត ទោះតាមពាក្យសម្តី លិខិត ឬគំនូរ។ បទល្មើសនេះ ត្រូវពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀល ទៅ ១០ ០០០ ០០០(ដប់លាន)រៀល។

### ២.៣.៧.ដែនកំណត់នៃការផ្សព្វផ្សាយតាមសេចក្ដីព្រាងច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត

បទល្មើស និងទោសចំពោះការបំពានសិទ្ធិលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត តាមសេចក្ដីព្រាងច្បាប់ស្ដីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតមានដូចខាងក្រោម៖

- មាត្រា២៧ បទល្មើសពាក់ព័ន្ធនឹង រូបអាសអាភាសកុមារ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន)រៀល។
- មាត្រា២៨ បទល្មើសពាក់ព័ន្ធនឹង ខ្លឹមសារនិងគេហទំព័រ ជនណាដែលប្រព្រឹត្តអំពើណាមួយដូចជា៖ តាក់តែងមាតិកាព័ត៌មានដែលធ្វើឱ្យអន្តរាយដល់ឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា, ធ្វើការផ្សព្វផ្សាយខ្លឹមសារអ្វីដែលនាំឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហឹង្សា, ផ្សព្វផ្សាយខ្លឹមសារឬផ្សាយបន្តនូវព័ត៌មានដែលបណ្ដាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ, ផ្សព្វផ្សាយខ្លឹមសារ ឬផ្សព្វផ្សាយបន្តព័ត៌មានមិនពិតដែលជាការជេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ, ផ្សព្វផ្សាយខ្លឹមសារអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិជាអាទិ៍ ព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន និងស្ថានភាពដទៃទៀត អត្ថបទឬរូបអាសអាភាស និងរូបភាពនៃអំពើហឹង្សា ការមួលបង្កាច់ បរិហាកេរ្តិ៍ និងការជេរប្រមាថ រូបភាពដែលប្រមាថមើលងាយប្រៀបធៀបមនុស្សទៅនឹងសត្វតិរច្ឆាន, តាក់តែងខ្លឹមសារគំរាមគំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលដល់ ៦ ០០០ ០០០ (ប្រាំមួយលាន)រៀល។ ចំពោះប្រភេទនៃការគំរាមគំហែងត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

### ២.៣.៨.ការកំណត់បទល្មើស និងទោសផ្សេងៗទៀត

លើសពីការកំណត់បទល្មើស និងទោស ដែលបានបកស្រាយខាងលើរួចមក ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក៏បានកំណត់ផងដែរនូវបទល្មើស និងទោសមួយចំនួន មានដូចខាងក្រោម៖

- មាត្រា៤២៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ (បទក្លែងព័ត៌មាន), ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំទៅ ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន)រៀល ទៅ ៤ ០០០ ០០០(បួនលាន)រៀល អំពើផ្ដល់ ឬបើកកកាយព័ត៌មានក្លែង ដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម ឬការធ្វើឱ្យខូចខាត ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស។

- មាត្រា៤៩៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់), ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្តៈ ១.ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ។ ២.ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឱ្យសាធារណជនមើល។ ៣.ដោយគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់សាធារណជន។
- មាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ (បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ជាអាទិ៍), អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយដែលមានចែងក្នុងមាត្រា៤៩៤(លក្ខខណ្ឌអត្ថិភាពនៃការញុះញង់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន)រៀល ទៅ ៤ ០០០ ០០០(បួនលាន)រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ។
- មាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ (បទញុះញង់ឱ្យមានការរើសអើង), អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា៤៩៤(លក្ខខណ្ឌអត្ថិភាពនៃការញុះញង់)នៃក្រមនេះឱ្យប្រព្រឹត្តការរើសអើង ការគុំកួន ឬហិង្សា ចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពិន្ទុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់នោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន)រៀលទៅ៦ ០០០ ០០០(ប្រាំមួយលាន)រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ។

លើសពីនេះទៅទៀត **ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្នាំ២០០៥** ក៏បានកំណត់បទល្មើស និងទោសដែលពាក់ព័ន្ធនឹងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវៈ

- មាត្រា៤ នៃច្បាប់នេះ បានកំណត់ថា "ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ ចំពោះជនស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា។"។

ចំពោះទោសវិញ គឺត្រូវបានកំណត់នៅត្រង់មាត្រា២៣ ដែលមានសេចក្តីថា "ជនណាដែលផលិត ធ្វើពាណិជ្ជកម្ម នាំឆ្លងកាត់ នាំចេញ នាំចូល ឬស្តុកនូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ដល់ ១០(ដប់)ឆ្នាំ។

## ២.៤.ផលប៉ះពាល់នៃការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត

នៅក្នុងការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត អាចមានទាំងផលវិជ្ជមាន និងផលអវិជ្ជមាន។ វា អាស្រ័យទៅលើកម្រិតនៃការប្រើប្រាស់សិទ្ធិបានសមស្រប គិតប្រយោជន៍ទូទៅជាធំ ការយល់ដឹងរបស់អ្នកប្រើប្រាស់សិទ្ធិ អំពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើ និងការប្រើប្រាស់សិទ្ធិប្រកបដោយការទទួលខុសត្រូវ គោរពសិទ្ធិអ្នកដទៃ និងស្របតាមការកំណត់របស់ច្បាប់។ ការសិក្សាស្រាវជ្រាវនេះ សូមលើកឡើងពីផលប៉ះពាល់មួយចំនួន នៃការអនុវត្តសិទ្ធិរបស់បុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ដែលអាចនឹងកើតមានឡើងក្នុងទិដ្ឋភាពសំខាន់ៗមួយចំនួនដូចជា សេដ្ឋកិច្ច(២.៤.១) សង្គម(២.៤.២) និងវប្បធម៌(២.៤.៣)។

### ២.៤.១.ទិដ្ឋភាពខាងសេដ្ឋកិច្ច

ការផ្សព្វផ្សាយរបស់បុគ្គលនៅតាមប្រព័ន្ធអ៊ីនធឺណិតអាចនឹងផ្តល់ផលប៉ះពាល់ដល់ទិដ្ឋភាពខាងសេដ្ឋកិច្ច ទាំងផលវិជ្ជមាន និងអវិជ្ជមាន ដែលមានមួយចំនួនដូចខាងក្រោម៖

**ក.ផលវិជ្ជមាន**

- ជំរុញដល់ការធ្វើទំនាក់ទំនងពាណិជ្ជកម្ម តាមរយៈព័ត៌មានដែលទទួលបានត្រឹមត្រូវ
- ជួយដល់ការសម្រេចចិត្តរបស់អ្នកវិនិយោគ ធុរជន
- អាចពង្រីកទីផ្សារផលិតផល និងការលក់ដូរទំនិញ តាមរយៈការផ្សព្វផ្សាយ
- ទទួលបានព័ត៌មានត្រឹមត្រូវមកពីការផ្សព្វផ្សាយ អាចជួយកាត់បន្ថយពេលវេលា សេវា និងថវិកាក្នុងការផ្ទៀងផ្ទាត់ខាងផ្លូវច្បាប់
- ព័ត៌មានត្រឹមត្រូវ អាចកាត់បន្ថយហានិភ័យនៃការឆបោកប្រាក់កាសតាមប្រព័ន្ធអ៊ីនធឺណិត ជាដើម។

**ខ.ផលអវិជ្ជមាន**

- បំផ្លាញទំនុកចិត្តដៃគូពាណិជ្ជកម្ម ប្រសិនបើផ្សាយព័ត៌មានមិនពិត
- ផ្តល់ភាពស្មុគស្មាញដល់វិនិយោគិន ធុរជន ក្នុងការសម្រេចចិត្តចូលមកធ្វើការវិនិយោគ ជាពិសេសវិនិយោគិនពីបរទេស
- ចរន្តសេដ្ឋកិច្ច និងសកម្មភាពពាណិជ្ជកម្មនានា នឹងខាតបង់ដោយសារការឆបោក ការក្លែងបន្លំ(ការលក់ផលិតផលក្លែងក្លាយ ការក្លែងកម្មសិទ្ធិបញ្ញា...)តាមប្រព័ន្ធអ៊ីនធឺណិត ធ្វើឱ្យសេដ្ឋកិច្ចជួបហានិភ័យ និងទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់
- ត្រូវចំណាយថវិកាលើការជួលសេវាការពារផ្លូវច្បាប់(មេធាវី) ដើម្បីធានាភាពត្រឹមត្រូវស្របច្បាប់ និងដើម្បីដោះស្រាយបញ្ហាខាងផ្លូវច្បាប់ដែលអាចនឹងកើតចេញពីការផ្សព្វផ្សាយ
- បង្កការខាតបង់ប្រាក់កាស បើមានការឆបោកតាមប្រព័ន្ធអ៊ីនធឺណិត ជាដើម។

**ករណីជាក់ស្តែង៖** ការផ្សព្វផ្សាយរបស់អង្គការសង្គមស៊ីវិលមួយចំនួន ក៏បានផ្តល់ជាផលអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាផងដែរ។ ឧទាហរណ៍ ការផ្សព្វផ្សាយពាក់ព័ន្ធការរឹតត្បិតលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពនៅកម្ពុជា ជាឫសគល់មួយធ្វើឱ្យអង្គការសហគមន៍អឺរ៉ុបសម្រេចចិត្តដកប្រព័ន្ធអនុគ្រោះពន្ធ (EBA) ផ្នែកខ្លះចេញពីកម្ពុជា។ ដូច្នេះ ធ្វើឱ្យវិនិយោគិនមួយចំនួនមានការស្ទាក់ស្ទើរក្នុងការមកវិនិយោគនៅកម្ពុជា ឬក៏ធ្វើការសម្រេចចិត្តដកការវិនិយោគនៅកម្ពុជាទៅវិនិយោគនៅប្រទេសជិតខាងវិញ។

### ២.៤.២.ទិដ្ឋភាពខាងសង្គម

ការផ្សព្វផ្សាយរបស់បុគ្គលនៅតាមប្រព័ន្ធអ៊ីនធឺណិត អាចនឹងផ្តល់ផលប៉ះពាល់ដល់ទិដ្ឋភាពខាងសង្គម ទាំងផលវិជ្ជមាន និងអវិជ្ជមាន ដែលមានមួយចំនួនដូចខាងក្រោម៖

**ក.ផលវិជ្ជមាន**

- បង្កើនទំនុកចិត្តគ្នាទៅវិញទៅមក តាមរយៈព័ត៌មានពេញលេញ ត្រឹមត្រូវ
- មានស្ថិរភាពសង្គម សណ្តាប់ធ្នាប់ សន្តិសុខ ភាពស្ងប់ស្ងាត់ក្នុងការរស់នៅ
- ប្រជាពលរដ្ឋមានសុខភាពផ្លូវចិត្ត ប្រាសចាកពីការរស់នៅក្នុងភាពរឹកររដោយសារព័ត៌មានបំពុលសង្គម ដែលបង្កការភ័យខ្លាច
- បង្កើនបរិយាកាសសង្គមប្រជាធិបតេយ្យ និងការគោរពសិទ្ធិគ្នា។

**ខ.ផលអវិជ្ជមាន**

- បំផ្លាញទំនុកចិត្តគ្នា បើព័ត៌មានមិនត្រឹមត្រូវ (fake news)
- អស្ថិរភាព គ្មានសណ្តាប់ធ្នាប់ និងចលាចលក្នុងសង្គម
- ប្រជាពលរដ្ឋត្រូវរស់នៅក្នុងភាពភ័យខ្លាច ប្រយ័ត្នប្រយែងគ្រប់ជំហាន និងនាំមកនូវជំងឺផ្លូវចិត្ត ជំងឺបាក់ស្បាត ស្ត្រេស ជាដើម។

**ករណីជាក់ស្តែង៖** ការផ្សព្វផ្សាយ ដែលអាចផ្តល់ជាផលប៉ះពាល់ដល់សង្គមដូចជា ការបង្កចលាចល អសន្តិសុខ ចោរកម្ម ឬការរើសអើងពូជសាសន៍ជាដើម។ តួយ៉ាង ការផ្សព្វផ្សាយពីការរកឃើញករណីជនជាតិខ្មែរអ៊ីស្លាម ដែលបានទៅប្រារព្ធពិធីសាសនានៅប្រទេសម៉ាឡេស៊ីបានឆ្លងជំងឺកូវីដ១៩ ធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនមានការរើសអើងជនជាតិខ្មែរអ៊ីស្លាមដោយមិនលក់ ឬមិនទិញរបស់ជនជាតិខ្មែរអ៊ីស្លាម។ បន្ថែមពីនេះ ក្នុងអំឡុងពេលមានការផ្ទុះការឆ្លងជំងឺកូវីដ១៩ខ្លាំង ធ្វើឱ្យលេចចេញនូវសារសំឡេងមិនពិតពាក់ព័ន្ធនឹង "រាជរដ្ឋាភិបាលគ្រោងបិទរាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលវីរុសកូវីដ១៩"។ ព័ត៌មាននេះបានធ្វើឱ្យមានការចលាចលដល់ប្រជាពលរដ្ឋនាំគ្នាសម្រុកទៅទិញអង្ករ មី និងម្ហូបអាហារដែលទុកបានយូរធ្វើជាស្បៀង និងផ្តល់ជាផលលំបាកដល់អ្នកដែលមានជីវភាពខ្វះខាតក្នុងការទិញទំនិញទុក ស្របជាមួយគ្នានោះផងដែរ វាផ្តល់ជាផល

ប្រយោជន៍ដល់អាជីវករមួយចំនួនតូចឆ្លៀតឱកាសដំឡើងថ្លៃទំនិញ ព្រោះឃើញមានការកើនឡើងនៃតម្រូវការរបស់ប្រជាពលរដ្ឋ និងទំនិញសម្រាប់ផ្គត់ផ្គង់មានកម្រិត។ ហេតុនេះ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល បានចេញសេចក្តីប្រកាសព័ត៌មាន ដោយច្រានចោលទាំងស្រុង នូវសារជាសំឡេងដែលលាក់ប្រភព ត្រូវបានចែកចាយតាមបណ្តាញសង្គម ផ្សព្វផ្សាយថា *«រាជរដ្ឋាភិបាលគ្រោងបិទរាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលវីរុសកូវីដ១៩»*។ អង្គភាពអ្នកនាំពាក្យបាន សូមគោរពអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ កុំមានការភ្ញាក់ផ្អើលស្លន់ស្លោ ដែលនាំឱ្យមានភាពចលាចលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងជាពិសេសបង្កឱ្យឡើងថ្លៃទំនិញហួសហេតុ ដោយមិនសមហេតុសមផល។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ១២៣/២០ អអរ

សេចក្តីប្រកាសព័ត៌មាន

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** សូមច្រានចោលទាំងស្រុង នូវសារជាសំឡេងដែលលាក់ប្រភព ត្រូវបានចែកចាយតាមបណ្តាញសង្គម ផ្សព្វផ្សាយថា *រាជរដ្ឋាភិបាលគ្រោងបិទរាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលវីរុសកូវីដ ១៩*។

**អង្គភាពអ្នកនាំពាក្យ** សូមគោរពជម្រាបជូនសាធារណជន មេត្តាជ្រាបថា រាជរដ្ឋាភិបាលបានបង្កើត *គណៈកម្មការជាតិប្រយុទ្ធនឹងជម្ងឺកូវីដ១៩* ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធាន ក៏ដូចជាឥស្សរជនជាន់ខ្ពស់នៃរាជរដ្ឋាភិបាលជាច្រើនរូប ជាអនុប្រធាន រួមទាំង **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាអនុប្រធានប្រចាំការ បានដាក់ចេញនូវវិធានការយ៉ាងម៉ឺងម៉ាត់ជាទីបំផុត និងជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលវីរុសកូវីដ១៩។

**អង្គភាពអ្នកនាំពាក្យ** សូមគោរពអំពាវនាវសារជាថ្មី ដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ កុំមានការភ្ញាក់ផ្អើលស្លន់ស្លោ ដែលនាំឱ្យមានភាពចលាចលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងជាពិសេសបង្កឱ្យឡើងថ្លៃទំនិញហួសហេតុ ដោយមិនសមហេតុសមផល។

**អង្គភាពអ្នកនាំពាក្យ** សូមបញ្ជាក់ថា ប្រភពព័ត៌មានពិតប្រាកដ និងផ្លូវការពីស្ថានការណ៍វីរុសកូវីដ ១៩ គឺជាប្រភពចេញពីក្រសួងសុខាភិបាល។ លើសពីនេះទៀត ប្រសិនបើប្រជាពលរដ្ឋទាំងអស់ មានចម្ងល់ផ្សេងៗ សូមទំនាក់ទំនងលេខទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងសុខាភិបាល១១៥ ឬលេខទូរស័ព្ទទាន់ហេតុការណ៍របស់ **អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល** ០៧០ ៨០៨ ៩៨៨, ០៨៨ ៧ ០៣៧ ៩៧២, ០៧៨ ៦៣១ ៦៦៩។/

ថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០

ប្រភព៖ https://dap-news.com/national/2020/03/24/43435/

រូបភាពទី ២.៤៖ សេចក្តីប្រកាសព័ត៌មានរបស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដើម្បីច្រានចោលការផ្សព្វផ្សាយព័ត៌មានមិនពិត ពាក់ព័ន្ធនឹងការបិទរាជធានីភ្នំពេញ។

**២.៤.៣.ទិដ្ឋភាពខាងវប្បធម៌**

ការផ្សព្វផ្សាយរបស់បុគ្គលនៅតាមប្រព័ន្ធអ៊ីនធឺណិត អាចនឹងផ្តល់ផលប៉ះពាល់ដល់ទិដ្ឋភាពខាងវប្បធម៌ ទាំងផលវិជ្ជមាន និងអវិជ្ជមាន ដែលមានមួយចំនួនដូចខាងក្រោម៖

**ក.ផលវិជ្ជមាន**

- លើកកម្ពស់ការផ្សព្វផ្សាយវប្បធម៌ ទំនៀមទម្លាប់បានទូលំទូលាយជាងមុន
- បង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋលើផ្នែកវប្បធម៌ តាមរយៈព័ត៌មានដែលទទួលបានមានភាពសម្បូរបែប
- ជួយពង្រីកចំណេះដឹង និងសម្រួលដល់ការសិក្សាស៊ីជម្រៅរបស់សិស្ស និស្សិត ជាដើម។

**ខ.ផលអវិជ្ជមាន**

- បំផ្លាញគ្រឹះវប្បធម៌ អត្តសញ្ញាណជាតិ តាមរយៈរូបភាពសង្គមមិនល្អ(ចាប់តាំងពីការបោះពុម្ពផ្សាយស្នាដៃមិនត្រឹមត្រូវ ការប្រើប្រាស់ភាសាមិនសមរម្យ ការស្លៀកពាក់លេចលើលេចក្រោម)
- នាំមកនូវការយល់ដឹងខុស ប្រាសចាកភាពថ្លៃថ្នូរ គុណតម្លៃ តាមរយៈព័ត៌មានបំពុល
- បាត់បង់នូវគោលការណ៍សីលធម៌សង្គម ការរស់នៅស្អាតស្អំ និងការគោរពសិទ្ធិគ្នា ជាដើម។

**ជាឧទាហរណ៍ក្នុងទិដ្ឋភាពសង្គមជាក់ស្តែង៖** ការផ្សព្វផ្សាយដែលផ្តល់ជាផលអវិជ្ជមានដល់វប្បធម៌ ដូចជាការបង្ហោះនូវរូបភាពមិនសមរម្យរបស់បុគ្គលមួយចំនួនតាមបណ្តាញសង្គម និងការផ្សព្វផ្សាយនូវវប្បធម៌របស់ជាតិសាសន៍ដទៃ ដោយមិនលើកតម្កើងនូវវប្បធម៌របស់ជាតិខ្លួន អាចធ្វើឱ្យកូនខ្មែរជំនាន់ក្រោយមានការយល់ច្រឡំ និងមិនស្គាល់ពីវប្បធម៌របស់ខ្លួន។ បុគ្គលមួយចំនួន ធ្វើការផ្សព្វផ្សាយបរិហាកេរ្តិ៍គ្នាទៅវិញទៅមកនៅពេលដែលមានទំនាស់រវាងគ្នានិងគ្នា។ ជាក់ស្តែង ក្នុងបណ្តាញសង្គមហ្វេសប៊ុក មនុស្សធ្វើការហែកហួរគ្នាដោយគ្មានការអៀនខ្មាស់ ព្រោះតែចង់ល្បី ឬចង់ឈ្នះរឿងខ្លួន។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជាសរុបសេចក្តីមក បុគ្គលមានសិទ្ធិនិងសេរីភាពក្នុងការផ្សព្វផ្សាយនៅតាមប្រព័ន្ធអ៊ីនធឺណិត ដែលត្រូវបានបញ្ញត្តទទួលស្គាល់ដោយវិធានច្បាប់ មានទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ដើម្បីសិក្សាឈ្វេងយល់អំពី «សិទ្ធិផ្សព្វផ្សាយរបស់បុគ្គលនៅលើប្រព័ន្ធអ៊ីនធឺណិត» ការសិក្សាស្រាវជ្រាវនេះ បានផ្តោតទៅលើសញ្ញាណទូទៅនៃសិទ្ធិលើការផ្សព្វផ្សាយ ដោយក្នុងនោះមានការសិក្សាពីនិយមន័យ និងសញ្ញាណនៃសិទ្ធិលើការផ្សព្វផ្សាយដែលមានចែងទាំងក្នុងក្របខ័ណ្ឌច្បាប់ជាតិនិងច្បាប់អន្តរជាតិ និងបន្ទាប់មកទៀត គឺការសិក្សាបានផ្តោតទៅលើការអនុវត្តសិទ្ធិនេះនៅលើប្រព័ន្ធអ៊ីនធឺណិត ដោយបានលើកពីសិទ្ធិនិងសេរីភាព ដែនកំណត់នៃសិទ្ធិ បទល្មើសនិងទោស និងផលប៉ះពាល់នៃការអនុវត្តសិទ្ធិនេះនៅតាមប្រព័ន្ធអ៊ីនធឺណិត។

ជាការពិតណាស់ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតបានជួយសម្រួលទៅដល់បុគ្គលគ្រប់មជ្ឈដ្ឋានទូទៅទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ ក្នុងការផ្សព្វផ្សាយ ចែករំលែកព័ត៌មាន ឬដំណឹងបានយ៉ាងទូលំទូលាយ ឆាប់រហ័ស និងចំណេញទាំងពេលវេលានិងថវិកា។ ក៏ប៉ុន្តែ ទន្ទឹមនឹងភាពងាយស្រួលនេះដែរ ចំពោះការផ្សព្វផ្សាយ ការចែកចាយព័ត៌មានផ្សេងៗ ប្រសិនបើបុគ្គលពុំបានយល់ដឹងអំពីច្បាប់ និងបំពានច្បាប់ មានជាអាទិ៍ ការផ្សព្វផ្សាយប៉ះពាល់ដល់ឯកជនភាពរបស់បុគ្គល ប្រពៃណី វប្បធម៌ជាតិ សាសនា សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ស្ថិរភាពនយោបាយ។ល។ បុគ្គលអាចនឹងត្រូវទទួលខុសត្រូវខាងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា សិទ្ធិលើការផ្សព្វផ្សាយមួយចំនួនតាមប្រព័ន្ធអ៊ីនធឺណិតក៏ត្រូវបានកម្រិតផងដែរ ដែលតាមរយៈការសិក្សាស្រាវជ្រាវនេះ បានលើកឡើងនៅក្នុងក្របខ័ណ្ឌមួយចំនួនដូចជា ពាណិជ្ជកម្ម សារព័ត៌មាន សុខាភិបាល កម្មសិទ្ធិបញ្ញា វប្បធម៌ជាតិ ជីវិតឯកជនរបស់បុគ្គល និងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ជាដើម។

បញ្ហាដែលកើតមានសព្វថ្ងៃ មានដូចជា កង្វះការយល់ដឹងផ្នែកច្បាប់របស់អ្នកផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត និងម្យ៉ាង ច្បាប់មួយចំនួននៅពុំទាន់មាន និងច្បាប់ចាស់ដែលមានស្រាប់ពុំទាន់បានធ្វើបច្ចុប្បន្នភាព។ កង្វះការយល់ដឹងផ្នែកច្បាប់របស់អ្នកផ្សព្វផ្សាយ ដោយសារការយល់ដឹងអំពីច្បាប់ផ្នែកនេះ គឺនៅមានកម្រិតថ្វីត្បិតតែប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ចំណែកឯប្រជាពលរដ្ឋទៀតសោត នៅពុំទាន់សម្បូរទៅដោយអ្នកចេះដឹងច្បាប់ច្រើន ហើយប្រសិនជាច្បាប់ត្រូវបានរឹតបណ្តឹងកាន់តែខ្លាំង នោះផលប៉ះពាល់នឹងកើតមានឡើងជាពិសេសប្រជាពលរដ្ឋ ដែលនៅតំបន់ដាច់ស្រយាល និងពុំសូវមានចំណេះដឹង។

កង្វះការអនុវត្តច្បាប់ និងការយល់ដឹងពីច្បាប់ទៅលើការផ្សព្វផ្សាយរបស់ពលរដ្ឋ ធ្វើឱ្យពួកគាត់ពុំបានចូលរួមអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងជាហេតុធ្វើឱ្យមានផលប៉ះពាល់ដល់បុគ្គលផ្ទាល់ និងដល់សេដ្ឋកិច្ច សង្គម រួមទាំងវប្បធម៌ជាតិ។ ជាក់ស្តែង បុគ្គលមួយចំនួន បានធ្វើការផ្សព្វផ្សាយដោយបំពាន ដូចជា ករណីផ្សព្វផ្សាយ

ព័ត៌មានក្លែងក្លាយទាក់ទងនឹងរឿងជំងឺកូវីដ១៩, ការលួចចម្លងស្នាដៃចម្រៀងតែងនិពន្ធពីសម័យដើម, និងការបង្ហោះនូវរូបភាពសិុចសុី ស្រើបស្រាលទាញផលប្រយោជន៍លក់ផលិតផលរបស់ខ្លួន ជាដើម។ សព្វថ្ងៃ ច្បាប់មួយចំនួននៅពុំទាន់រត់តាមសម័យកាលនៅឡើយ ព្រោះថា សម័យនេះ គឺជាសម័យបោះជំហានទៅរកបច្ចេកវិទ្យាឌីជីថល ហើយច្បាប់មួយចំនួនត្រូវបានតាក់តែងឡើងជាយូរឆ្នាំមកហើយ នៅពេលដែលយកមកអនុវត្តនាពេលបច្ចុប្បន្ន គឺពុំទាន់មានសង្គតិភាពរវាងគ្នានៅឡើយ។

លើសពីនេះទៅទៀត ដោយសារតែបច្ចេកវិទ្យាមានការវិវត្តឥតឈប់ឈរ និងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតមានការរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ បញ្ហាចោទនៅតែមានបន្តទៀតថា តើនៅថ្ងៃអនាគតសិទ្ធិផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត អាចត្រូវបានកំណត់នៅក្នុងវិស័យណាផ្សេងទៀត? ហើយបទល្មើសនៃការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ អាចនឹងកើតមានក្រោមរូបភាពយ៉ាងដូចម្ដេច?

# អនុសាសន៍

# អនុសាសន៍

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដ៏ផូរផង់ដោយអរិយធម៌ វប្បធម៌ ជាកេរដំណែលពីដូនតា ដែលបានឆ្លុះបញ្ចាំងតាមរយៈប្រវត្តិសាស្ត្រ ក៏ប៉ុន្តែ ចំពោះការគ្រប់គ្រងទៅលើការផ្សព្វផ្សាយនៅតាមប្រព័ន្ធអ៊ីនធឺណិតសព្វថ្ងៃ បើទោះបីជាកម្ពុជាមានច្បាប់មួយចំនួនសម្រាប់កំណត់រួចទៅហើយក្តី ក៏នៅពុំទាន់មានការអនុវត្តបានដោយបុគ្គលមួយចំនួននៅឡើយ។

ទាញចេញពីការពន្យល់បកស្រាយលើប្រធានបទ «**សិទ្ធិបុគ្គលលើការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត**» ការសិក្សាស្រាវជ្រាវនេះ បានលើកនូវចំណុចខ្វះខាតមួយចំនួនមកបង្ហាញ សម្រាប់ជាការចូលរួមចំណែកក្នុងការជំរុញការអនុវត្តច្បាប់ សណ្តាប់ធ្នាប់រៀបរយសង្គម។ ហើយនិងដើម្បីចូលរួមជំរុញឱ្យការអនុវត្តច្បាប់នៅកម្ពុជាកាន់តែមានភាពប្រសើរ ការសិក្សាស្រាវជ្រាវនេះ ក៏សូមចូលរួមលើកជាមតិយោបល់ ដូចខាងក្រោម៖

**សម្រាប់ពលរដ្ឋជាអ្នកផ្សព្វផ្សាយ៖**

- មុននឹងធ្វើការផ្សព្វផ្សាយជាសាធារណៈលើបណ្តាញសង្គម ( Youtube, Facebook, Telegram, …) សូមមេត្តាគិតពិចារណាថា យើងផ្សព្វផ្សាយ(post), ចែកផ្សាយ(share),...នោះនាំឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ សណ្តាប់ធ្នាប់ ឬទំនៀមទម្លាប់ល្អរបស់សង្គមដែរឬទេ?
- សម្រាប់សិទ្ធិបុគ្គលឯកជន ជាពិសេស នីតិអត្តវិស័យនៃបូរណភាពផ្លូវចិត្ត។ បុគ្គលម្នាក់ៗ មានកិត្តិយស សេចក្តីថ្លៃថ្នូររៀងៗខ្លួន ប្រសិនបើអ្នក ផ្សព្វផ្សាយ(post), ចែកផ្សាយ(share) នៅក្នុងវិសាលភាពនៃច្បាប់ហាមឃាត់ នោះអ្នកផ្សព្វផ្សាយ និងចែកផ្សាយ ត្រូវទទួលទណ្ឌកម្ម និង /ឬ ទោស។
- សម្រាប់សណ្តាប់ធ្នាប់សាធារណៈ និងផលប្រយោជន៍ជាតិ សូមលោកអ្នកផ្សព្វផ្សាយ មេត្តាគិតថា ការផ្សព្វផ្សាយរបស់លោកអ្នក ផ្តល់សេចក្តីអន្តរាយដល់ផលប្រយោជន៍សង្គមជាតិ វប្បធម៌ កេរ្តិ៍ឈ្មោះ សេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិដែរឬទេ? ការណ៍នេះរឹតតែសំខាន់ សូមបងប្អូនប្រជាពលរដ្ឋយើងដែលមានឈាមជ័រជាខ្មែរ ត្រូវតែស្រលាញ់ជាតិ ប្រពៃណី វប្បធម៌ដ៏ល្អផូរផង់ និងត្រូវរក្សាកេរដំណែលដែលបានបន្សល់ទុកពីដូនតាយើងតទៅទៀតឱ្យបានគង់វង្ស គ្មានថ្ងៃសាបរលាបពេលណាមួយឡើយ។
- សូមអ្នកបង្កើតស្នាដៃជំនាន់ក្រោយ មេត្តាគួរតែចេះគោរពស្នាដៃរបស់រៀមច្បង និងមរតកដើម។ រក្សាតម្លៃរៀមច្បង មិនបំបាត់ឈ្មោះដើម និងអភិវឌ្ឍគំនិតថ្មី ស្នាដៃថ្មី ប្រកបដោយគុណភាព និងកិត្តិភាព។ អាស្រ័យហេតុនេះ សូមបងប្អូន ដែលប្រើប្រាស់បណ្តាញសង្គមនានា គួរតែចេះគោរពសេចក្តីថ្លៃថ្នូរសម្រាប់សង្គមជាតិ និងជីវិតឯកជនរបស់អ្នកដទៃ ពីព្រោះថា ជនជាតិខ្មែរ ជាពូជអម្បូរដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងប្រៀបដូចពេជ្រពណ្ណរាយ និងជាជនជាតិមួយដែលមានការអត់ធ្មត់ខ្ពស់ ចេះដាប់ថ្ម ឆ្លាក់កសាងអង្គរវត្តនិងប្រាសាទនានា ប្រកបដោយក្បូរក្បាច់រចនារស់រវើកដូចមានជីវិតពិតៗ និងបានជាមហាសម្បត្តិ

បេតិកភណ្ឌពិភពលោកដែលពុំអាចនឹងកាត់ថ្លៃបាន។ ដូច្នេះ សូមកុំធ្វើឱ្យពូជខ្មែរខូចកេរ្តិ៍ឈ្មោះ។

- **សូមអ្នកផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត** មុននឹងធ្វើការផ្សព្វផ្សាយ ឬចែកចាយបន្ត គួរតែសិក្សាឈ្វេងយល់ឱ្យបានច្បាស់លាស់ និងរក្សា បង្ហាញពីប្រភពព័ត៌មាន ដែលបានផ្សព្វផ្សាយ ឬចែកចាយបន្តនោះ។

**សម្រាប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច៖**

- គួរតែមានការបញ្ជ្រាបការយល់ដឹងផ្នែកច្បាប់ពាក់ព័ន្ធនឹងការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតដល់សាធារណជន ដូចជា ការផ្សព្វផ្សាយជាវីដេអូក្លីបខ្លីៗ ទាក់ទងនឹងសិទ្ធិអ្នកផ្សព្វផ្សាយវិធានការហាមឃាត់ ទណ្ឌកម្ម និងទោសដែលកើតឡើងពីការបំពាននិងពីអំពើល្មើសច្បាប់។
- ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ គួរតែរៀបចំច្បាប់ថ្មីដែលពុំទាន់មាននៅឡើយ មានដូចជា៖ ច្បាប់ការពារទិន្នន័យឯកជនភាព(Data Privacy Protection Regulation) ដើម្បីការពារព័ត៌មានឯកជនភាពពីការផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណិត, ច្បាប់សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត(Cyber Security Law) ដើម្បីការពារសុខសុវត្ថិភាពខាងព័ត៌មានវិទ្យានៅលើអ៊ីនធឺណិត, និងច្បាប់គ្រប់គ្រងច្រកទ្វារអ៊ីនធឺណិត(Law on Internet Gateway) ដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រងនិងស្វែងរកចាប់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសនៅលើបណ្តាញទំនាក់ទំនងសង្គមនៃក្រុមហ៊ុនវេទិកាឌីជីថល(Digital Platform) ដូចជា Facebook, Instagram, Twitter, Telegram ជាដើម។
- រាជរដ្ឋាភិបាល លោកគួរតែពន្លឿនការអនុម័តសេចក្តីព្រាងច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា(Cyber Crime Law) ឱ្យបានទាន់សភាពការណ៍ សមស្របទាន់ពេលវេលា។

ការសិក្សាស្រាវជ្រាវនេះ សង្ឃឹមនិងជឿជាក់ថា បងប្អូនប្រជាពលរដ្ឋយើង នឹងបានចូលរួមចំណែក **អនុវត្តសិទ្ធិផ្សព្វផ្សាយតាមតាមប្រព័ន្ធអ៊ីនធឺណិត** ដើរតាមវិធានច្បាប់ ព្រមទាំងគោរពសិទ្ធិបុគ្គលលើជីវិតឯកជន បោះជំហានឆ្ពោះទៅរកវឌ្ឍនភាពសង្គម និងកិត្តិភាពជាតិ។

# ឯកសារយោង

# ឯកសារយោង

## បទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

២. ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១០០៩/០២២, ៣០ វិច្ឆិកា ២០០៩។

៣. ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

៤. ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, លេខ នស/រកម/១១១៩/០១៧, ២ វិច្ឆិកា ២០១៩។

៥. ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ, លេខ នស/រកម/១២០៧/០៣៧, ២៨ ធ្នូ ២០០៧។

៦. ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ, លេខ នស/រកម/០៦០៥/០១៦, ១ មិថុនា ២០០៥។

៧. ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ០៥ មីនា ២០០៣។

៨. ច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ, លេខ នស/រកម/១១០០/១០, ៣ វិច្ឆិកា ២០០០។

៩. ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា, លេខ នស/រកម/០៦០០/០០១, ២១ មិថុនា ២០០០។

១០. ច្បាប់ស្តីពីរបបសារព័ត៌មាន, លេខ នស/រកម/០៨៩៥/០៧, ០១ កញ្ញា ១៩៩៥។

១១. សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត, (សេចក្តីព្រាងច្បាប់នេះពុំបានបញ្ជាក់កាលបរិច្ឆេទ)។

១២. អនុក្រឹត្យស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់, លេខ ៣៥ អនក្រ/បក, ២៤ កុម្ភៈ ២០១១។

១៣. អនុក្រឹត្យស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ, លេខ ១៣៣ អនក្រ/បក, ១៨ វិច្ឆិកា ២០០៥។

១៤. ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា, លេខ ១៧០ ប្រក/អន្តក្រ, ២៨ ឧសភា ២០១៨។

១៥. ប្រកាសស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈ, លេខ ១៦១ ប្រ.ក, ១៤ តុលា ២០១៦។

១៦. ប្រកាសរួមស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបុរាណ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ, លេខ ៧៥/០៦ ពម/ប្រក របស់ក្រសួងព័ត៌មាន និងលេខ ០០៧ អនស/ម/ព របស់ក្រសួងសុខាភិបាល, ២១ កុម្ភៈ ២០០៦។

១៧. សេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាពិន័យនិងលើកសរសើរ, លេខ ២៧ សសរ, ១៩ មីនា ២០២០។

## បទដ្ឋានគតិយុត្តអន្តរជាតិ

១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តនិងប្រកាសដោយសេចក្តីសម្រេចចិត្ត នៃមហាសន្និបាតលេខ ២១៧ A(III) នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

២. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។

## សៀវភៅអេឡិចត្រូនិក

១. ក្រុមប្រឹក្សាជាតិភាសាខ្មែរ. *សទ្ទានុក្រមវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ខ្មែរ-អង់គ្លេស-បារាំង.* ភ្នំពេញ៖ ផ្នែកបោះពុម្ព ផ្សព្វផ្សាយនិងបណ្តុះបណ្តាលនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិភាសាខ្មែរ, ឆ្នាំ២០១៤. http://rac.gov.kh/researchs?page=4 (បានចូលពិគ្រោះនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០)។

២. ក្រសួងផែនការ. *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ៖ វិទ្យាស្ថានជាតិស្ថិតិ, ឆ្នាំ២០១៩. http://www.nis.gov.kh/nis/Census2019/Provisional%20Population%20Census%202019_Khmer_FINAL.pdf (បានចូលពិគ្រោះនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០)។

៣. ទីស្តីការគណៈរដ្ឋមន្ត្រី. *សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណីនិងនីតិវិធីរដ្ឋប្បវេណី.* បោះពុម្ពលើកទី១. ភ្នំពេញ៖ គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, ឆ្នាំ២០០៧. https://lawlibrarysite.wordpress.com/សទ្ទានុក្រម/ (បានចូលពិគ្រោះនៅថ្ងៃទី២៥ខែមិថុនាឆ្នាំ២០២០)។

៤. ពុទ្ធសាសនបណ្ឌិត្យ. *វចនានុក្រមខ្មែរ,* បោះពុម្ពលើកទី៥. ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦៧។

៥. James Lewis. *Economic Impact of Cybercrime No Slowing Donw*. ២០១៨. https://www.csis.org/analysis/economic-impact-cybercrime (បានចូលពិគ្រោះនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០)។

## គេហទំព័រ

១. http://thekhmerdaily.com/article/46498 (បង្ហាញពីចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតចល័តនៅកម្ពុជា) (បានចូលពិគ្រោះនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០)។

២. https://www.csis.org/analysis/economic-impact-cybercrime (បង្ហាញអំពីចំនួនថវិការបស់ពិភពលោកដែលបានខាតបង់ព្រោះតែឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត)(បានចូលពិគ្រោះនៅថ្ងៃទី៣ មិថុនា ២០២០)។

៣. https://www.cambodiaip.gov.kh/TemplateThree.aspx?parentId=45&menuid=46&childMasterMenuId=46 (ពន្យល់អំពីនិយមន័យនៃសិទ្ធិអ្នកនិពន្ធ)(បានចូលពិគ្រោះនៅថ្ងៃទី៥ខែសីហា ឆ្នាំ២០២០)។

៤. https://www.rfi.fr/km/copyright-law (ការក្សាសិទ្ធិ៖ តើអ្នកនិពន្ធស្នាដៃទទួលបានការការពារបែបណាខ្លះ?) (បានចូលពិគ្រោះនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០)។

# ឧបសម្ព័ន្ធ

# តារាងបញ្ជីឧបសម្ព័ន្ធ

| ឧបសម្ព័ន្ធ | បរិយាយ |
| --- | --- |
| ឧបសម្ព័ន្ធ ក | -ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៨។ |
| ឧបសម្ព័ន្ធ ខ | -ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥។ |
| ឧបសម្ព័ន្ធ គ | -ប្រកាសស្តីពីក្រមសីលធម៌នៃអ្នកសិល្បៈ ឆ្នាំ២០១៦។<br>-សេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាពិន័យនិងលើកសរសើរ ឆ្នាំ២០២០។ |
| ឧបសម្ព័ន្ធ ឃ | -មាត្រា៣០២, ៣០៥, ៣០៧, ៤២៥, ៤៩៤, ៤៩៥, ៤៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។<br>-មាត្រា៧៦២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ |
| ឧបសម្ព័ន្ធ ង | -ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ឆ្នាំ២០០០។<br>-អនុក្រឹត្យស្តីពីវិធានការហាមឃាត់ចំពោះការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ ឆ្នាំ២០១១។ |
| ឧបសម្ព័ន្ធ ច | កម្រងករណីសិក្សា |

# ឧបសម្ព័ន្ធ ច
## កម្រងករណីសិក្សា

# តារាងកម្រងករណីសិក្សា

| ករណី | បរិយាយ |
|---|---|
| គ្រឿងសម្អាង | -ករណីទី១៖ ការផ្សព្វផ្សាយគ្រឿងសម្អាងគ្មានលេខប្រវេទន៍ និងគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល<br>-ករណីទី២៖ ការផ្សព្វផ្សាយលក់ផលិតផលគ្រឿងសម្អាងគ្មានលេខប្រវេទន៍ និងគ្មានច្បាប់អនុញ្ញាតឱ្យផ្សព្វផ្សាយពីក្រសួងសុខាភិបាល |
| ឧបករណ៍បរិក្ខារពេទ្យ និងសារធាតុសម្លាប់មេរោគ | -ករណីទី១៖ រឿងផ្សព្វផ្សាយលក់ឱសថ ឧបករណ៍បរិក្ខារពេទ្យ និងសារធាតុសម្លាប់មេរោគ<br>-ករណីទី២៖ រឿងផ្សព្វផ្សាយលក់ម៉ាស់ អាល់កុល ឧបរណ៍វាស់សីតុណ្ហភាព និងសារធាតុសម្លាប់មេរោគ គ្មានលេខបញ្ជិកា<br>-ករណីទី៣៖ ការផ្សព្វផ្សាយ និងចរាចរលក់ផលិតផលអាល់កុល ក៏ដូចជាផលិតផលលាងសម្អាតដៃ និងផលិតផលផ្សេងទៀត |
| ផលិតផលជំនួយអារម្មណ៍ផ្លូវភេទ | ករណី៖ ផ្សព្វផ្សាយលក់ ផលិតផលជំនួយអារម្មណ៍ផ្លូវភេទនារី គ្មានបញ្ជិកា |
| ព័ត៌មានមិនពិត | មាន១២ករណី |
| ការផ្សព្វផ្សាយប៉ះពាល់ឯកជនភាព | -ករណី៖ ផ្សព្វផ្សាយបញ្ចេញអត្តសញ្ញាណអ្នកជំងឺ |
| សេចក្តីណែនាំ និងជូនដំណឹងរបស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា | -ករណីទី១៖ ប្រទេសសឹង្ហបុរី<br>-ករណីទី២៖ TikTok<br>-ករណីទី៣៖ ហ្គេម<br>-ករណីទី៤៖ ZOOM<br>-ករណីទី៥៖ FACEBOOK<br>-ករណីទី៦៖ AI (Artificial Intelligence) |
| វប្បធម៌ទំនៀមទម្លាប់ ប្រពៃណីជាតិ | -ករណីទី១៖ សម្តែងរួមគ្នាដោយបានបញ្ចេញកាយវិការស្រើបស្រាល<br>-ករណីទី២៖ រឿងច្រៀង និពន្ធ បទចម្រៀងដែលបង្កប់អត្ថន័យប៉ះពាល់ដល់សីលធម៌សង្គម និងវប្បធម៌ខ្មែរ |